BRITISH COUNCIL

គាំទ្រដោយ

Foreign, Commonwealth & Development Office

# The Climate Connection

# ការប្រែប្រួលអាកាសធាតុ និងការអប់រំរបស់កុមារ៖ កញ្ចប់ធនធានសម្រាប់សាលារៀន













# តើធនធាននេះសម្រាប់អ្នកណា?

ធនធាននេះត្រូវបានរចនាឡើងសម្រាប់លោកគ្រូអ្នកគ្រូ និងអ្នកសម្របសម្រួលក្នុងការអប់រំសម្រាប់មនុស្សវ័យក្មេងដែលមានអាយុពី ១១ ដល់ ១៧ ឆ្នាំ។ វាអាចត្រូវបានប្រើនៅក្នុងសាលារៀនទូទៅ និងនៅក្នុងការកំណត់ជាភាសាអង់គ្លេសផងដែរ។

ធនធាននេះមានគោលបំណងលើកកម្ពស់ការយល់ដឹង និងសកម្មភាពដែលមានព័ត៌មានជុំវិញបញ្ហា និងការផ្សារភ្ជាប់គ្នារវាងការប្រែប្រួលអាកាសធាតុ និងការអប់រំរបស់កុមារី។

ក្នុងប្រាំមួយមេរៀន (ជំហាន) សិស្សានុសិស្សនឹង៖

- ស្វែយល់អំពីសារៈសំខាន់ជាបន្ទាន់នៃការដោះស្រាយការប្រែប្រួលអាកាសធាតុ និងសារៈសំខាន់នៃយុត្តិធម៌អាកាសធាតុ
- ស្វែយល់អំពីរបៀបដែលគ្រោះមហន្តរាយពាក់ព័ន្ធនឹងអាកាសធាតុ ជារឿយៗជះឥទ្ធិពលលើវិសមភាពយេនឌ័រដែលមានស្រាប់ និងអំពីរបៀបដែលការអប់រំកុមារីអាចទទួលបានផលប្រយោជន៍គ្រប់យ៉ាងពីសង្គមក្នុងការបន្ស៊ាំ និងកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ខណៈដែលមានការជំរុញឲ្យសង្គមមានយុត្តិធម៌កាន់តែប្រសើរ និងនិរន្តរភាព
- សិក្សាពីសកម្មជនយុវជនផ្សេងទៀតជុំវិញពិភពលោក និងគិតអំពីដំណាក់កាលផ្សេងៗដែលអាចចូលរួមបានក្នុងការរៀបចំផែនការសម្រាប់សកម្មភាពសង្គម។។

ជាផ្នែកមួយនៃការសិក្សារបស់យុវជនទាំងនោះ សិស្សានុសិស្សនឹងមានឱកាសអភិវឌ្ឍជំនាញស្នូលក្នុងការពិចារណា និងដោះស្រាយបញ្ហា, ភាពជាពលរដ្ឋ, ភាពជាអ្នកដឹកនាំរបស់សិស្សានុសិស្ស, ភាពច្នៃប្រឌិត, និងការស្រមើស្រមៃ និងទិដ្ឋភាពនានានៃអក្ខរកម្មឌីជីថល។ ពួកគេក៏អាចមានឱកាសចូលរួមក្នុងភាពជាដៃគូអន្តរជាតិ និងចែករំលែកសកម្មភាព និងការសិក្សាមួយចំនួនជាមួយសាលាដៃគូផងដែរ។



## ក្រុមអាយុ

សកម្មភាពទាំងនេះត្រូវបានរចនាឡើងសម្រាប់ប្រើជាមួយសិស្សានុសិស្សដែលមានអាយុពី ១១ ដល់ ១៧ ឆ្នាំ។ សកម្មភាពមួយចំនួនអាចត្រូវបានកែសម្រួលសម្រាប់ប្រើជាមួយសិស្សានុសិស្សដែលក្មេងជាងនេះ។ ក៏ដូចជាការពិចារណាអំពីរបៀបដែលល្អបំផុតក្នុងការសម្របឯកសារទាំងនេះឲ្យសមស្របទៅនឹងតម្រូវការ និងសមត្ថភាពរបស់អ្នកសិក្សាម្នាក់ៗ យើងលើកទឹកចិត្តឲ្យលោកគ្រូអ្នកគ្រូគិតអំពីរបៀបអនុវត្តការសិក្សាឲ្យមានប្រសិទ្ធភាពបំផុតក្នុងបរិបទនៃសហគមន៍ជាក់លាក់ និងកម្មវិធីសិក្សាថ្នាក់ជាតិនៃប្រទេសរបស់ខ្លួន។ លោកគ្រូអ្នកគ្រូក៏ប្រហែលជាត្រូវគិតផងដែរអំពីរបៀបដែលខ្លួនពិភាក្សាអំពីបញ្ហាអំពើហិង្សាផ្អែកលើយេនឌ័រឲ្យស្របទៅតាមកម្រិតអាយុ ហើយត្រៀមខ្លួនដើម្បីឆ្លើយតបទៅនឹងចម្លើយផ្សេងៗរបស់សិស្សានុសិស្ស ឬបញ្ជូនសិស្សានុសិស្សទៅបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវដែលអាចដោះស្រាយកង្វល់នានាអំពីប្រធានបទនេះបាន។

## ការតម្រឹមកម្មវិធីសិក្សា

ឯកសារធនធាននេះ មានទំនាក់ទំនងទៅនឹងភាសាអង់គ្លេស វិទ្យាសាស្ត្រសង្គម ការអប់រំសង្គមផ្ទាល់ខ្លួន និងការអប់រំសុខភាព ភាពជាពលរដ្ឋ វិទ្យាសាស្ត្រ និងគណិតវិទ្យា។ មេរៀនសិក្សានេះក៏ត្រូវបានរៀបចំឡើងដើម្បីគាំទ្រដល់គោលដៅ អភិវឌ្ឍប្រកបដោយ ចីរភាពជាសកល (SDGs) របស់អង្គការសហប្រជាជាតិ ជាពិសេសគោលដៅទី ៥៖ សមភាពយេនឌ័រ និងគោលដៅទី ១៣៖ សកម្មភាពអាកាសធាតុ។ តាមរយៈការក្លាយទៅជាពលរដ្ឋដែលទទួលបានព័ត៌មាន និងចូលរួមពេញលេញ យុវជននឹងមានលទ្ធភាពប្រសើរជាងមុនក្នុងការចូលរួមចំណែករបស់ខ្លួនទៅនឹងអនាគតដែលកាន់តែមានភាពសមធម៌ និងនិរន្តរភាព

## ទិដ្ឋភាពទូទៅនៃប្រធានបទសម្រាប់លោកគ្រូអ្នកគ្រូ និងអ្នកសម្របសម្រួល

នៅទូទាំងពិភពលោក មនុស្សកាន់តែយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ។ ព្រឹត្តិការណ៍អាកាសធាតុខ្លាំងដូចជារលកកម្តៅ ទឹកជំនន់ និងខ្យល់ព្យុះកំពុងក្លាយជារឿងធម្មតា និងមានឥទ្ធិពលបំផ្លិចបំផ្លាញលើសហគមន៍ជុំវិញពិភពលោក។ របាយការណ៍ចុងក្រោយបង្អស់របស់អ្នកវិទ្យាសាស្ត្រអាកាសធាតុឈានមុខគេរបស់ពិភពលោក បញ្ជាក់កាន់តែច្បាស់ជាងនេះទៅទៀតថាសកម្មភាពរបស់មនុស្សកំពុងផ្លាស់ប្តូរអាកាសធាតុតាមរបៀបដែលមិនធ្លាប់មានពីមុនមក ហើយជួនកាលមិនអាចត្រលប់វិញបាន។ ជាការឆ្លើយតបរបស់អង្គការសហប្រជាជាតិបានប្រកាស "កូដក្រហមសម្រាប់មនុស្សជាតិ"។ ដើម្បីទប់ស្កាត់ការឡើងកម្តៅលើសពី ១,៥°C យើងត្រូវកាត់បន្ថយការបំភាយឧស្ម័ន ៧,៦ ភាគរយជារៀងរាល់ឆ្នាំ ចាប់ពីឆ្នាំនេះដល់ឆ្នាំ ២០៣០។ (UNEP 2019[1])

មនុស្សជាច្រើនប្រហែលជាមិនបានដឹងពីទំនាក់ទំនងរវាងការអប់រំរបស់កុមារី និងការប្រែប្រួលអាកាសធាតុទេ។ មូលនិធិ Malala[2] បានប៉ាន់ប្រមាណថា នៅឆ្នាំ ២០២១ ព្រឹត្តិការណ៍ពាក់ព័ន្ធនឹងអាកាសធាតុនឹងរារាំងកុមារីយ៉ាងហោចណាស់ ៤ លាននាក់នៅក្នុងប្រទេសដែលមានចំណូលមធ្យមកម្រិតទាប និងទាបពីការបញ្ចប់ការសិក្សារបស់ពួកគេ។ ប្រសិនបើនិន្នាការបច្ចុប្បន្ននៅតែបន្ត នៅឆ្នាំ ២០២៥ ការប្រែប្រួលអាកាសធាតុនឹងក្លាយជាកត្តារួមចំណែកក្នុងការរារាំងកុមារីយ៉ាងហោចណាស់ ១២,៥ លាននាក់ពីការបញ្ចប់ការសិក្សារបស់ពួកគេជារៀងរាល់ឆ្នាំ។ សិស្សានុសិស្សដែលរងការលំបាក និងជាពិសេសកុមារីរងគ្រោះច្រើនជាងអ្នកដទៃ៖

... ជាមួយនឹងកុមារីអាយុចូលរៀននៅមធ្យមសិក្សាភាគច្រើនប្រឈមមុខនឹងការឈប់រៀន ឬរៀបការមុនអាយុ ដោយសារគ្រួសាររបស់ពួកគេធ្លាក់ក្នុងភាពក្រីក្រ។ គេរំពឹងថានឹងមានអាពាហ៍ពិពាហ៍កុមារ ២,៥ លាននាក់បន្ថែមទៀតនៅក្នុងរយៈពេល ៥ ឆ្នាំខាងមុខ និងកុមារីជំទង់ជាង ១ លាននាក់នឹងមានផ្ទៃពោះក្នុងរយៈពេល ១២ ខែខាងមុខ។ អត្រានៃអំពើហិង្សាយេនឌ័រដែលប៉ះពាល់ដល់កុមារីត្រូវបានគេគិតថាមានការកើនឡើងទ្វេដងធៀបនឹងពេលដែលសាលាបើក (ពោលគឺពី ៨% ទៅ ១៧%) [...] នៅទូទាំងពិភពលោក កុមារីវ័យជំទង់យ៉ាងហោចណាស់ ២០០ លាននាក់រស់នៅជួរមុខនៃវិបត្តិអាកាសធាតុ ហើយអ្នកដែលត្រូវបាត់បង់ឱកាសតាមរយៈភាពក្រីក្រ, ចំណាកស្រុក, ឬពិការភាពទំនងជារងផលប៉ះពាល់ខ្លាំងបំផុត។ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមានសភាពខ្លាំងក្លាណាស់នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ហើយកុមារីរងផលលំបាកទ្វេដងដោយសារតែសេចក្តីរំពឹងទុកសង្គមលើតួនាទីរបស់ពួកគេ។[3]

នៅពេលដែលកុមារីទៅសាលារៀន ពួកគេបានរៀនជំនាញក្នុងការត្រៀមទុកជាមុន និងជំនះនូវវិបត្តិនានាពាក់ព័ន្ធនឹងអាកាសធាតុ ដូចជាសមត្ថភាពនៃការគិតពិចារណាដែលចាំបាច់សម្រាប់ដំណើរការ និងចាត់វិធានការនៅពេលមានការរាយការណ៍អំពីអាកាសធាតុ។ ការអប់រំក៏បង្កើនៈ ភាពធន់នឹងអាកាសធាតុ និងសមត្ថភាពក្នុងការសម្របខ្លួន (ដូចជាជំនាញពិចារណាតាមលំដាប់លំដោយ និងជំនាញប្រាស្រ័យទាក់ទង ដើម្បីមានលទ្ធភាពយល់ដឹងនិងពន្យល់អំពីហានិភ័យទាំងឡាយដល់អ្នកដទៃ)។ ការអប់រំក៏ធ្វើឲ្យជំនាញគិតពិចារណាមានលក្ខណៈជាប្រព័ន្ធ (ដូចជាការយល់ដឹងអំពីថាតើសកម្មភាពមនុស្ស ដូចជាការកាប់បំផ្លាញព្រៃឈើ អាចនឹងចូលរួមចំណែកទៅនឹងការបាក់ដី និងទឹកជំនន់យ៉ាងណាខ្លះ)។ ហើយការអប់រំក៏កសាងជំនាញភាពជាអ្នកដឹកនាំសម្រាប់ការចងក្រង។ កុមារីដែលបានចូលរៀន ក៏ទំនងជាអាចប្រលូកក្នុងសកម្មភាពរួមបានច្រើន និងក្នុងប្រព័ន្ធផ្លាស់ប្តូរមួយឆ្ពោះទៅរកនិរន្តរភាព។

ប្រទេសដែលបានវិនិយោគលើការអប់រំរបស់កុមារី មានអត្រាមរណភាពពីគ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់តិចជាងប្រទេសដែលមានកម្រិតអប់រំរបស់កុមារីទាប2 ។ ការអប់រំរបស់កុមារី ជាពិសេសនៅកម្រិតមធ្យមសិក្សា ត្រូវបានគេកំណត់ថាជាកត្តាសង្គមសេដ្ឋកិច្ចដ៏សំខាន់បំផុត ដើម្បីកាត់បន្ថយភាពងាយរងគ្រោះចំពោះផលប៉ះពាល់នៃគ្រោះមហន្តរាយដែលពាក់ព័ន្ធនឹងអាកាសធាតុ និងការប្រែប្រួលអាកាសធាតុធ្ងន់ធ្ងរ។

ជារឿយៗ ចលនាធ្វើកូដកម្មនៅតាមសាលារៀនដើម្បីអាកាសធាតុគឺដឹកនាំដោយយុវជន ដោយធ្វើតាមឧទាហរណ៍របស់ Greta Thunberg និង Vanessa Nakate ពីព្រោះពួកគាត់ភាពច្រើនមានអារម្មណ៍ថាការអប់រំរបស់ខ្លួនពុំបានធ្វើឲ្យគាត់ត្រៀមខ្លួនសម្រាប់ការប្រែប្រួលដ៏ឆាប់រហ័ស និងអនាគតមិនប្រាកដប្រជាមួយ។ លោកគ្រូអ្នកគ្រូចាំបាច់ផ្តល់ភាពអង់អាចដល់យុវជន ដើម្បីឲ្យពួកគាត់ក្លាយទៅជាពលរដ្ឋមានចំណេះដឹងគ្រប់គ្រាន់ ដើម្បីចាត់វិធានការបែបជាវិជ្ជមាន។ ចំណេះដឹងតែម៉្យាងគឺមិនទាន់គ្រប់គ្រាន់ទេ៖

*ការស្រាវជ្រាវបានបង្ហាញថា អភិក្រមប្រជាធិបតេយ្យនឹងមានការចូលរួមចំពោះការសិក្សា មានសារៈសំខាន់ណាស់ដើម្បីលើកទឹកចិត្តសិស្សានុសិស្សឲ្យចាត់វិធានការលើចំណេះដឹងដែលខ្លួនកំពុងសិក្សា។ ការអប់រំប្រភេទនេះ មិនត្រឹមតែអំពីទស្សនទាន និងតថភាពប៉ុណ្ណោះទេ ប៉ុន្តែវាជាការឆ្លុះបញ្ចាំងជុំវិញលើហេតុ និងផលនៃការប្រែប្រួលអាកាសធាតុតាមរយៈការផ្លាស់ប្តូរមតិយោបល់គ្នាជាមួយមិត្តភក្តិ។ ការសិក្សាមានការចូលរួមជួយឲ្យសិស្សានុសិស្សឲ្យអភិវឌ្ឍជំនាញពិចារណាដោយឯករាជ្យ និងបង្កើនចំណេះដឹងរបស់ខ្លួនពាក់ព័ន្ធនឹងកិច្ចការនយោបាយ ដែលអនុញ្ញាតឲ្យពួកគាត់អាចស្រមើស្រមៃឃើញអំពីអនាគតមួយផ្សេង និងចាត់វិធានការឆ្ពោះទៅកាន់អនាគតរបស់ខ្លួន។ (មូលនីធិម៉ាឡាឡា)*

[1] https://www.unep.org/explore-topics/climate-action/facts-about-climate-emergency

[2] អនាគតដ៏បៃតង និងយុត្តិធម៌ជាងមុន៖ ហេតុអ្វីបានជាអ្នកដឹកនាំត្រូវវិនិយោគលើអាកាសធាតុ និងការអប់រំកុមារី (មូលនិធិ Malala 2021)

[3] កុមារីគ្រប់រូបទៅសាលារៀន រក្សាសុវត្ថិភាព និងរៀន៖ សកម្មភាពប្រាំឆ្នាំជាសកល 2021-26 (FCDO 2021)

## អភិក្រមអប់រំការប្រែប្រួលអាកាសធាតុ

ការអប់រំការប្រែប្រួលអាកាសធាតុ ចាំបាច់មានអភិក្រមពេញមួយសាលារៀន ដែលដាក់បញ្ចូលជនគ្រប់រូបស្មើៗគ្នា និងជំរុញឲ្យមានការសិក្សាបរិវត្តកម្ម និងសកម្ម។ ផ្នែកនេះផ្តល់នូវចំណេះដឹងជាមូលដ្ឋានដល់លោកគ្រូអ្នកគ្រូ ដូច្នេះពួកគេអាចចូលរួមជាមួយសិស្សានុសិស្ស និងសហគមន៍សាលារបស់ពួកគេប្រកបដោយអត្ថន័យដើម្បីយល់ដឹង និងចាត់វិធានការ លើការប្រែប្រួលអាកាសធាតុ។

លំនាំខាងក្រោមត្រូវបានផ្តល់ជាឯកសារមូលដ្ឋាន សម្រាប់លោកគ្រូអ្នកគ្រូឲ្យយល់អំពីការអប់រំសិទ្ធិមនុស្ស និងអភិក្រមគ្រប់ជ្រុងជ្រោយដ៏មានសក្តានុពលក្នុងការបង្កើតសាលារៀនប្រកបដោយនិរន្តរភាព។

លំនាំផ្សេងៗត្រូវបានបង្កើតឡើងដើម្បីគាំទ្រការអប់រំសិទ្ធិមនុស្សសម្រាប់យុវជន។ ដ្យាក្រាម ១ ខាងក្រោមបង្ហាញពីអន្តរកម្មរវាង 'ចំណេះដឹងអំពី' 'ជំនាញសម្រាប់' និង 'គុណតម្លៃតាមរយៈ' ពាក់ព័ន្ធនឹង ការអប់រំការប្រែប្រួលអាកាសធាតុ។

មនុស្សត្រូវការ "ចំណេះដឹងអំពី" ការប្រែប្រួលអាកាសធាតុ៖ វិទ្យាសាស្ត្រ, គំនិតសម្រាប់ការបន្ធូរបន្ថយ, និងការបន្សាំអ្វីដែលអាចនឹងកើតឡើងនាពេលអនាគត។ ពួកគេត្រូវការ "ជំនាញសម្រាប់"៖ ការត្រិះរិះពិចារណា, ការដោះស្រាយបញ្ហា, ការធ្វើការងារជាក្រុម, ការប្រាស្រ័យទាក់ទង, ការសន្ទនា។ ពួកគេក៏ត្រូវការ "គុណតម្លៃតាមរយៈ"៖ បង្កើតទម្លាប់ និងអាកប្បកិរិយា ដើម្បីរស់នៅប្រកបដោយនិរន្តរភាព, កាត់បន្ថយការបំភាយឧស្ម័នកាបូន, ប្រព្រឹត្តចំពោះមនុស្សគ្រប់រូបដោយយុត្តិធម៌ និងដោយក្តីគោរព។ កញ្ចប់នេះបានរួមបញ្ចូលអភិក្រមនេះតាមរយៈការចែករំលែកចំណេះដឹង, ការអភិវឌ្ឍជំនាញតាមរយៈសកម្មភាពដែលបានស្នើផ្សេងៗ, និងតាមរយៈការជួយយុវជនក្នុងការអភិវឌ្ឍគុណតម្លៃដើម្បីចូលរួមប្រកបដោយអត្ថន័យជាមួយដំណោះស្រាយនៃការប្រែប្រួលអាកាសធាតុ។




ដ្យាក្រាម ១៖ យកមកពី Lister (១៩៨៤)[4]

ប្រសិនបើកញ្ចប់ធនធាននេះកំពុងត្រូវបានប្រើប្រាស់ជាផ្នែកមួយនៃអភិក្រមរួម ក្នុងការបង្កើតសាលារៀនដែលមិនប៉ះពាល់ដល់បរិស្ថាន នោះលំនាំដែលបង្ហាញក្នុងដ្យាក្រាម ២ ខាងក្រោមអាចជួយរៀបចំរចនាសម្ព័ន្ធដំណើរការនៃការកំណត់ឱកាសក្នុងការផ្លាស់ប្តូរផ្នែកសំខាន់ៗឲ្យកាន់តែមានលក្ខណៈគិតគូរដល់បរិស្ថានកាន់តែខ្លាំង។ ការអនុវត្តតាមលំនាំនេះត្រូវបានចែករំលែកជាមួយសិស្សានុសិស្សនៅក្នុងជំហានទី ៤ ផ្នែកទី ២ ដើម្បីផ្តល់នូវក្របខ័ណ្ឌសម្រាប់ពួកគេ ដើម្បីកំណត់ចំណុចដែលពួកគេអាចចូលរួមដោយផ្ទាល់នៅក្នុងសាលារៀន និងសហគមន៍មូលដ្ឋានរបស់ខ្លួន។




ដ្យាក្រាម ២៖ ៤Cs ៖ យកមកពី សាលានិរន្តរភាព DCSF (២០០៦)[5]

លំនាំ ៤Cs ត្រូវបានគេប្រើប្រាស់ជាមូលដ្ឋាននៃអភិក្រមរបស់សាលារៀនប្រកបដោយនិរន្តរភាពរបស់ចក្រភពអង់គ្លេស។ វាបង្ហាញអំពីសេចក្តីត្រូវការឲ្យមានអភិក្រមគ្រប់ជ្រុងជ្រោយមួយដែលផ្សារភ្ជាប់គ្នារវាងវប្បធម៌ កម្មវិធីសិក្សា សាលារៀន និងសហគមន៍។ (សូមមើលស្លាយ ២៨ )

**វប្បធម៌៖** របៀបដែលសាលារៀនលើកកម្ពស់បរិយាកាសនៃសមភាព និងបរិយាបន្ន ទើបអ្នកគ្រប់គ្នាមានអារម្មណ៍ថាបានចូលរួម និងមានលទ្ធភាពចូលរួមចំណែកឲ្យអស់ពីសមត្ថភាពរបស់ខ្លួន។ កុមារីត្រូវបានលើកទឹកចិត្តឲ្យសិក្សាមុខវិជ្ជា STEM ហើយកុមារាត្រូវបានលើកទឹកចិត្តឲ្យសិក្សាមុខវិជ្ជា "មើលថែទាំ" ។ ស្មារតីនៃការមើលថែទាំខ្លួនឯង មើលថែទាំគ្នាទៅវិញទៅមក និងមើលថែទាំពិភពលោក។

ត្រូវប្រាកដថាមានគោលនយោបាយក្មេងទំនើង និងការបៀតបៀនផ្លូវភេទស្រាប់ និងបានអនុវត្ត និងមានការរៀបវគ្គប្រជុំជាមួយសិស្សានុសិស្ស ដើម្បីបង្កើតនូវទំនាក់ទំនងល្អ និងស្មើភាពគ្នារវាងកុមារា និងកុមារី។ ភាពជាអ្នកដឹកនាំសាលារៀនតំណាងឲ្យតួនាទីជាន់ខ្ពស់របស់បុរស និងស្ត្រី។

[4] សូមមើលទំព័រទី ៦ សម្រាប់ព័ត៌មានលម្អិតអំពីគំរូនេះដែលត្រូវបានប្រើប្រាស់ដោយអង្គការលើកលែងទោសអន្តរជាតិចក្រភពអង់គ្លេសនៅក្នុងការបោះពុម្ពផ្សាយអប់រំសិទ្ធិមនុស្សរបស់ពួកគេ ពិភពលោករបស់យើង សិទ្ធិរបស់យើង៖ – https://www.amnesty.org.uk/files/2017-10/Our%20World%2C%20Our%20Rights.pdf?VersionId=zEeg9AtPenZxhRySN4JnnnN2zysVp.Lo



[5] នាយកដ្ឋានសម្រាប់កុមារ, សាលារៀន, និងគ្រួសារ https://webarchive.nationalarchives.gov.uk/ukgwa/20090608185221/http://www.teachernet.gov.uk/sustainableschools/leadership/leadership_detail.cfm?id=3

**កម្មវិធីសិក្សា៖** រួមមានសារៈសំខាន់នៃការសិក្សាអំពីការប្រែប្រួលអាកាសធាតុ និងវិទ្យាសាស្ត្រដែលពាក់ព័ន្ធ។ សិក្សាអំពីជំនាញ និងការងារបៃតងសម្រាប់អនាគតដែលគ្មានកាបូន។ សិក្សាជំនាញត្រិះរិះពិចារណា ការយល់ចិត្តគ្នា ការដោះស្រាយបញ្ហា ការធ្វើការងារជាក្រុម ការប្រាស្រ័យទាក់ទង និងការសន្ទនា។ ធានាថាសម្ភារៈឯកសារ និងលោកគ្រូអ្នកគ្រូមានការយល់ដឹងអំពីយេនឌ័រ និងមិនជំរុញឲ្យមានការរើសអើងយេនឌ័រ។ ធ្វើឲ្យប្រាកដថាមានក្លឹបសិក្សាក្រៅកម្មវិធីសិក្សាឲ្យស្មើៗគ្នាសម្រាប់កុមារា និងកុមារី (STEM និង ក្លឹបកីឡា ស្វាគមន៍កុមារី, ក្លឹបល្ខោន និងសិល្បៈស្វាគមន៍កុមារា)។

**បរិវេណសាលារៀន៖** គ្រប់គ្រងអគារសិក្សា និងទីធ្លាដើម្បីឲ្យមនុស្សគ្រប់គ្នាមានអារម្មណ៍ថាមានសុវត្ថិភាព និងមានតម្លៃ។ ធ្វើការឆ្ពោះទៅរកការកាត់បន្ថយកាបូន ប្រសិទ្ធភាពថាមពល និងការប្រើប្រាស់ថាមពលកកើតឡើងវិញ។ ផ្តល់កន្លែងសម្រាប់ធម្មជាតិលូតលាស់។ ធានាថាសម្ភារៈបរិក្ខារមានសុវត្ថិភាពសម្រាប់កុមារា និងកុមារីក្នុងការប្រើប្រាស់ដោយមានរបងព័ទ្ធជុំវិញ និងមានទីតាំងផ្លាស់ប្តូរសម្លៀកបំពាក់ និងការបោកគក់ដែលស្អាត និងមានសុវត្ថិភាពក្នុងការប្រើប្រាស់។

**សហគមន៍៖** របៀបដែលសាលារៀនចែករំលែកការសិក្សារបស់ខ្លួនជាមួយសហគមន៍ ទាំងសហគមន៍មូលដ្ឋានទាំងសហគមន៍សកលលោក។ ស្វែងរកមនុស្សនៅក្នុងសាលារៀន និងសហគមន៍ដ៏ធំទូលាយ ដែលអាចជួយសាលារៀនឲ្យកាន់តែបរិយាបន្ន, មាននិរន្តរភាព, និងមានមេត្រីភាពបរិស្ថាន។ ការជំរុញ និងការចូលរួមរបស់សហគមន៍ស្តីពីឥរិយាបថចំពោះអំពើហិង្សាផ្អែកលើយេនឌ័រ និងតួនាទីយេនឌ័រ។

ដូចបានលើកឡើងខាងលើ ចំណេះនាំឲ្យមានការយល់ដឹង ហើយបន្ទាប់មកនាំឲ្យមានសកម្មភាព រងការវាយប្រហារដោយមានការសិក្សាមួយចំនួនដែលថាចំណេះដឹង និងជំនាញមិនទាន់គ្រប់គ្រាន់ដើម្បីផ្លាស់ប្តូរឥរិយាបថនៅឡើយទេ។ ឯកសារទាំងនោះលើកឡើងថា៖ “មានកត្តាផ្ទាល់ខ្លួនជាច្រើន ដូចជាទំនាក់ទំនងយ៉ាងជ្រាលជ្រៅជាមួយធម្មជាតិ, ភាពពាក់ព័ន្ធរវាងបុគ្គល និងបញ្ហា, និងភ្នាក់ងារផ្ទាល់ខ្លួនចំពោះសកម្មភាព គឺជាធាតុសំខាន់ដែលចូលរួមចំណែកទៅនឹងកម្មវិធីផ្លាស់ប្តូរឥរិយាបថប្រកបដោយជោគជ័យមួយ” (Cordero et al 2020)។[6]

លោកគ្រូអ្នកគ្រូប្រហែលជាត្រូវធ្វើការលើផ្នែកទាំងនេះតាមបរិបទរបស់ខ្លួន ឧទាហរណ៍ការជួយយុវជនឲ្យបង្កើតទំនាក់ទំនងកាន់តែស៊ីជម្រៅជាមួយធម្មជាតិ (ការទទួលស្គាល់ និងគោរពការពឹងពាក់គ្នាទៅវិញទៅមករវាងភពផែនដី និងភាវៈរស់ទាំងអស់), ការស្វែងរកមធ្យោបាយ ដើម្បីធ្វើឲ្យបញ្ហាជាប់ពាក់ព័ន្ធនឹងខ្លួនឯងផ្ទាល់ និងការបង្កើតឲ្យមានភ្នាក់ងារផ្ទាល់ខ្លួន និងភ្នាក់ងាររួម ដើម្បីអាចផ្លាស់ប្តូរឥរិយាបថផ្ទាល់ខ្លួន និងឥរិយាបថរួម។

## ពេលវេលា និងធនធាន

ជំហាននីមួយៗតំណាងឲ្យមេរៀនរយៈពេលមួយម៉ោង ទោះបីជាជំហានទី ១ និងទី ៣ អាចទទួលបានអត្ថប្រយោជន៍កន្លះម៉ោងបន្ថែមក្នុងមួយម៉ោងនីមួយៗ ដើម្បីបញ្ចប់ក៏ដោយ។ ជំហានទី ១ និងទី ៤ តម្រូវឲ្យមានភ្ជាប់អ៊ីនធើណិតដើម្បីមើលភាពយន្ត ឬការបង្ហាញគ្រាប់ (មានការផ្តល់ជម្រើសគំហើញផ្សេងទៀតនៅក្នុងជំហានទី ១ ៖ មានការណែនាំសៀវភៅមួយក្បាលជាជម្រើសផ្សេងមួយទៀត ចំពោះការមើលភាពយន្តនៅក្នុងជំហានទី ៤)។



[6] Cordero, E.C., Centeno, D, Todd, A.M. (2020) តួនាទីនៃការអប់រំបម្រែបម្រួលអាកាសធាតុលើការបំភាយកាបូនពេញមួយជីវិត។ PLOS ONE 15(2): e0206266. https://doi.org/10.1371/journal.pone.0206266

# ទិដ្ឋភាពទូទៅនៃមេរៀន

## ជំហានទី ១៖ ការប្រែប្រួលអាកាសធាតុ

ការសិក្សាអំពីសារៈសំខាន់នៃការប្រែប្រួលអាកាសធាតុ អាកាសធាតុជះឥទ្ធិពលលើមនុស្សខុសៗគ្នាយ៉ាងណាខ្លះ និងវិធីមួយចំនួន ដើម្បីដោះស្រាយឫសគល់នៃការប្រែប្រួលអាកាសធាតុ។

## ជំហានទី ២៖ យុត្តិធម៌អាកាសធាតុ

ការស៊ើបអង្កេតថាតើនរណាជាអ្នកទទួលខុសត្រូវចំពោះការបំភាយឧស្ម័នអាកាសធាតុច្រើនជាងគេ និងថាតើសមភាព សមធម៌ និងយុត្តិធម៌មានទំនាក់ទំនងយ៉ាងណាទៅនឹងការប្រែប្រួលអាកាសធាតុ។

## ជំហានទី ៣៖ ការអប់រំរបស់កុមារី និង ការប្រែប្រួលអាកាសធាតុ

ការស្វែងយល់អំពីថាតើគ្រោះមហន្តរាយពាក់ព័ន្ធនឹងអាកាសធាតុ តែងតែពង្រីកវិសមភាពយេនឌ័រដែលមានស្រាប់យ៉ាងណា និងថាតើការអប់រំរបស់កុមារីអាចផ្ដល់អត្ថប្រយោជន៍ដល់សង្គមទាំងអស់យ៉ាងណាក្នុងការបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ ខណៈពេលដែលធ្វើឱ្យសង្គមមានភាពយុត្តិធម៌ និងនិរន្តរភាពជាងមុន។

## ជំហានទី ៤៖ ការពង្រឹងសមត្ថភាពយុវជន ចំពោះការប្រែប្រួលអាកាសធាតុ

ការសិក្សាពីសកម្មជនយុវជនផ្សេងទៀតមកពីជុំវិញពិភពលោក។ ការកំណត់ជំនាញមួយចំនួនដែលពាក់ព័ន្ធនឹងក្របខ័ណ្ឌ “ជំនាញបៃតង” ។ ការស្វែងយល់ពីការចូលរួម ការសិក្សាបរិវត្តកម្ម៖ ការផ្សារភ្ជាប់ទៅនឹងថ្នាក់រៀន វប្បធម៌ បរិវេណសាលារៀន និងសហគមន៍។

## ជំហានទី ៥៖ ការផ្លាស់ប្ដូរឥរិយាបថ ឬការផ្លាស់ប្ដូរប្រព័ន្ធ ?

ការពិចារណាអំពីគុណសម្បត្តិដែលទាក់ទងនៃការផ្លាស់ប្ដូរឥរិយាបថ និងការផ្លាស់ប្ដូរប្រព័ន្ធ។ ការគិតអំពីដំណាក់កាលដែលអាចពាក់ព័ន្ធក្នុងការរៀបចំផែនការសកម្មភាពសង្គម។

## ជំហានទី ៦៖ ការសម្តែងតួជុំវិញបញ្ហាប្រែប្រួលអាកាសធាតុក្នុងតំបន់

សិក្សាអំពីផលប៉ះពាល់ដែលអាចកើតមាននៃសកម្មភាពរុករករ៉ែថ្មជ្យូងថ្មលើសហគមន៍ ជាពិសេសពាក់ព័ន្ធនឹងទំនាក់ទំនងថាមពល តួនាទីយេនឌ័រ និងបទដ្ឋានសង្គម។ ការអភិវឌ្ឍការយោគយល់គ្នាចំពោះទស្សនៈផ្សេងៗគ្នា។ ឆ្លុះបញ្ចាំងអំពីការសិក្សាពាក់ព័ន្ធនឹងការចាត់វិធានការលើបញ្ហាយុត្តិធម៌អាកាសធាតុ។




[6] Cordero, E.C., Centeno, D, Todd, A.M. (2020) តួនាទីនៃការអប់រំបម្រែបម្រួលអាកាសធាតុលើការបំភាយកាបូនពេញមួយជីវិត។ PLOS ONE 15(2): e0206266. https://doi.org/10.1371/journal.pone.0206266

# គំរូផែនការរបស់គ្រូ

គំរូផែនការអាចត្រូវបានប្រើប្រាស់ជាលក្ខណៈបុគ្គល ដោយសហការជាមួយមិត្តរួមការងារនៅក្នុងសាលារៀនរបស់អ្នក ឬជាមួយគ្រូដែលបង្រៀនមេរៀនដូចគ្នានៅក្នុងប្រទេសមួយផ្សេងទៀត។

| សំណួរ | សម្គាល់ | ការគិតរបស់អ្នក |
|---|---|---|
| ១.តើអ្នកចង់ឲ្យសិស្សានុសិស្សសិក្សាអ្វីខ្លះ? | • អានឯកសារមេរៀនទាំងមូល ហើយពិចារណាថាអ្វីដែលសំខាន់បំផុតសម្រាប់សិស្សានុសិស្សក្នុងការសិក្សា។ ប្រើគោលបំណងសិក្សាដែលបានរាយនាមនៅដើមដំបូងនៃមេរៀននីមួយៗ ដើម្បីជួយអ្នកធ្វើកិច្ចការនេះ។<br>• តើអ្នកចង់បានលទ្ធផលអ្វីខ្លះសម្រាប់សិស្សានុសិស្សរបស់អ្នក?<br>• ពិចារណាលើជំនាញស្នូលដែលបានអភិវឌ្ឍឡើងដោយមេរៀននីមួយៗ។ តើអ្វីជាអាទិភាពក្នុងបរិបទរបស់អ្នក?<br>• គិតគូរថាតើមេរៀននេះសក្តិសមនឹងកម្មវិធីសិក្សាជាតិរបស់អ្នកយ៉ាងដូចម្តេច។ តើគោលបំណងសិក្សាឆ្លើយតបនឹងតម្រូវការនៃកម្មវិធីសិក្សាជាតិ ឬសេចក្តីណែនាំរបស់អ្នកយ៉ាងដូចម្តេចខ្លះ? | |
| ២. តើអ្វីជាវិធីដ៏ល្អបំផុតសម្រាប់ពួកគេក្នុងការសិក្សា? | • ចំពោះគោលបំណងសិក្សាដែលអ្នកបានកំណត់ ចូរសម្រេចចិត្តថាអ្នកនឹងបង្រៀនមេរៀនទាំងអស់ ឬមេរៀនតែមួយចំនួន។<br>• ពិចារណាអំពីពេលវេលា និងធនធានដែលអ្នកមាន។<br>• តើអ្នកត្រូវកែសម្រួលសកម្មភាពសិក្សាក្នុងមេរៀននីមួយៗ ដើម្បីបំពេញសេចក្តីត្រូវការរបស់សិស្សានុសិស្សដោយរបៀបណា?<br>• តើអ្នកនឹងប្រើប្រាស់សកម្មភាពបន្ថែមដែលបានស្នើដែរឬទេ?<br>• តើចំណេះដឹង និងជំនាញក្នុងមេរៀននេះផ្សារភ្ជាប់ទៅនឹងមេរៀនពីមុនយ៉ាងណាខ្លះ?<br>• តើវិធីសាស្រ្តអ្វីខ្លះដែលល្អបំផុត ដើម្បីឲ្យសិស្សានុសិស្សរៀនចេះអំពីថាតើវិសមភាពយេនឌ័រមានទំនាក់ទំនងយ៉ាងណាខ្លះជាមួយការប្រែប្រួលអាកាសធាតុនៅក្នុងសហគមន៍, ប្រទេសរបស់ខ្លួន, និងជាអន្តរជាតិ ហើយថាតើទំនាក់ទំនងនេះមានសភាពបែបណា ជាពិសេសសម្រាប់កុមារីនៅក្នុងបណ្តាប្រទេសដែលមានបទដ្ឋានយេនឌ័រវិសមភាព ដែលរារាំងកុមារីមិនឲ្យចូលរៀន ឬមិនឲ្យបញ្ចប់ការសិក្សារបស់ខ្លួន?<br>• តើមេរៀននេះអាចប្រើជាឱកាស ដើម្បីអភិវឌ្ឍជំនាញស្នូលដោយរបៀបណា?<br>• តើអ្វីជាវិធីដ៏ល្អបំផុតសម្រាប់សិស្សានុសិស្ស ដើម្បីឲ្យសិស្សានុសិស្សឈានដល់ការធ្វើការដោយសហការគ្នាយ៉ាងជិតស្និទ្ធ?<br>• អ្នកអាចចង់ឆ្លុះបញ្ចាំងពីការអនុវត្តគរុកោសល្យ ដែលគិតគូរលើយេនឌ័រ ដើម្បីធានាថាអ្នកបានប្រើវិធីសាស្រ្តបង្រៀន និងរចនាសម្ព័ន្ធភារកិច្ចជាក្រុមផ្សេងៗគ្នា ដើម្បីធានាឲ្យមានការចូលរួមពីសំណាក់កុមារី និងកុមារានៅក្នុងសកម្មភាពទាំងឡាយស្មើៗគ្នា។ | |

| សំណួរ | សម្គាល់ | ការគិតរបស់អ្នក |
|---|---|---|
| ៣.តើអ្នកដឹងថាតើសិស្សានុសិស្សបានរៀនអ្វីខ្លះតាមរបៀបណា ? | • ដោយយោងទៅនឹងគោលបំណងសិក្សាដែលអ្នកបានសម្រេចចិត្ត សូមគិតអំពីការវាយតម្លៃសិស្សានុសិស្ស។<br>• តើអ្នកធ្វើយ៉ាងណាដើម្បីឲ្យដឹងថាសិស្សានុសិស្សរបស់អ្នកបានដឹងអ្វីខ្លះ អំពីការប្រែប្រួលអាកាសធាតុ, វិទ្យាសាស្ត្រអាកាសធាតុ, ផលប៉ះពាល់, និងដំណោះស្រាយ មុនពេលចាប់ផ្តើមមេរៀននេះ ?<br>• ចូរពិចារណាថាតើអ្នកនឹងត្រូវការភស្តុតាងប្រភេទអ្វីខ្លះ ដើម្បីឲ្យដឹងថាសិស្សានុសិស្សពិតជាបានរៀនចំណេះ, ជំនាញ, និងគុណលក្ខណៈដែលអ្នកចង់ឲ្យពួកគេចេះ។ | |
| ៤. តើអ្នកត្រូវការធនធានអ្វីខ្លះ ? | • យោងតាមសកម្មភាពសិក្សាដែលអ្នកបានរៀបចំនៅក្នុងកិច្ចតែងការ ចូរគិតអំពីធនធានដែលអ្នកនឹងត្រូវការ។<br>• តើអ្នកអាចធ្វើការជាមួយនរណាខ្លះនៅក្នុងមេរៀននេះ ដើម្បីឲ្យសិស្សានុសិស្សរៀនបន្ថែមទៀតអំពីការអប់រំរបស់កុមារី និងការប្រែប្រួលអាកាសធាតុនៅក្នុងបរិបទរបស់ខ្លួនផ្ទាល់ និងបរិបទផ្សេងទៀត ?<br>• តើឯកសារបន្ថែមអ្វីខ្លះដែលនឹងមានប្រយោជន៍ដល់ការសិក្សារបស់សិស្សានុសិស្ស នៅក្នុងមេរៀននេះ ?<br>• តើអ្នកត្រូវការធ្វើសកម្មភាពនៅឯណា ? តើមានធនធានចាំបាច់ទាំងអស់ដែរឬទេ ? | |
| ៥. តើសិស្សានុសិស្សបានរៀនអ្វីខ្លះក្នុងមេរៀននេះ ? | • អំឡុងពេល និងក្រោយមេរៀន ចូរគិតថាតើសិស្សានុសិស្សបានរៀនអ្វីខ្លះ។<br>• តើសិស្សានុសិស្សសម្រេចបានគោលបំណងសិក្សាដល់កម្រិតណា ចំពោះមេរៀននីមួយៗ ?<br>• តើបានសម្រេចលទ្ធផលអ្វីផ្សេងទៀត ? តើសិស្សានុសិស្សបានរៀនអ្វីខ្លះទៀត ?<br>• តើសិស្សានុសិស្សយល់ច្រលំអំពីអ្វីខ្លះដែរឬទេ ?<br>• តើផ្នែកណាមួយនៃមេរៀន ដែលត្រូវការពេលវេលា ឬការយកចិត្តទុកដាក់ច្រើនជាងការរំពឹងទុក ? | |
| ៦. តើអ្នកមានការឆ្លុះបញ្ចាំងអ្វីផ្សេងទៀតអំពីមេរៀននេះ ? | • អំឡុងពេល និងបន្ទាប់ពីមេរៀន ចូរគិតថាតើអ្វីខ្លះដំណើរការល្អ និងអ្វីខ្លះដែលអ្នកអាចធ្វើខុសពីនេះ។<br>• តើបទពិសោធន៍សិក្សាណាខ្លះដែលមានគុណតម្លៃពិសេស ?<br>• តើសកម្មភាពសិក្សាសមស្របដែរឬទេ ? តើអ្វីខ្លះដំណើរការបានល្អ ?<br>• តើអ្នកនឹងធ្វើអ្វីខ្លះឲ្យខុសពីមុននៅពេលក្រោយ ? | |

# ជំហានទី ១៖ ការប្រែប្រួលអាកាសធាតុ

## គោលបំណងសិក្សា

នៅចុងបញ្ចប់នៃវគ្គ សិស្សានុសិស្សនឹងយល់អំពី៖

- ការប្រែប្រួលអាកាសធាតុពិតជាមានមែន, ការរីករាលដាល និងអាំងតង់ស៊ីតេ, ហើយមនុស្សគឺជាមូលហេតុចម្បង
- តើវិបត្តិអាកាសធាតុជះឥទ្ធិពលលើមនុស្សខុសៗគ្នាយ៉ាងណាខ្លះ
- មានមធ្យោបាយបច្ចេកទេស, ឥរិយាបថ, និងពាសពេញប្រព័ន្ធ ដើម្បីដោះស្រាយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

## ផ្នែកទី ១៖ តើអ្វីទៅជាការប្រែប្រួលអាកាសធាតុ ហើយហេតុអ្វីបានជាវាសំខាន់ ?

- ឲ្យសិស្សានុសិស្សធ្វើការជាគូ ដើម្បីពិភាក្សាសង្ខេបថាតើពួកគេយល់អ្វីខ្លះអំពីការប្រែប្រួលអាកាសធាតុ និងផ្តល់មតិត្រលប់អំពីគំនិតរបស់ខ្លួន។ សរសេរគំនិតទាំងនេះនៅលើក្តារខៀន។ ( ធានាថាសិស្សានុសិស្សគ្រប់គ្នាយល់អំពីភាពខុសគ្នារវាងធាតុអាកាស និងអាកាសធាតុ – សូមមើលនិយមន័យនៅក្នុងសទ្ទានុក្រម )

- បង្ហាញស្លាយទី ៤ និងឈុតភាពយន្តខាងក្រោម៖ https://www.youtube.com/watch?v=e7xW1MfXjLA&t=532s ការប្រែប្រួលអាកាសធាតុ ២០២១, មូលដ្ឋានវិទ្យាសាស្ត្ររូបវិទ្យា, របាយការណ៍វាយតម្លៃទី ៦ របស់ IPCC ឆ្នាំ ២០២២ ( ៨ នាទី ៤០ វិនាទី ដោយគ្មានក្រេឌីត )។

- ឲ្យសិស្សានុសិស្សដែលជាគូដដែល ពិភាក្សាអំពីចម្លើយរបស់ខ្លួនដោយសង្ខេប និងដើម្បីកំណត់សំណួរណាមួយ។ សរសេរសំណួរនៅលើក្តារខៀនបើមាន។

- ឲ្យសិស្សានុសិស្សធ្វើកិច្ចការផ្ទះ ដើម្បីស្វែងយល់ពីទស្សនៈរបស់សមាជិកគ្រួសារដែលមានវ័យចំណាស់ ថាតើមានការប្រែប្រួលអាកាសធាតុយ៉ាងដូចម្តេចខ្លះក្នុងរយៈពេល ២០ ឆ្នាំកន្លងមក ឬយូរជាងនេះ ដោយប្រើ "តើមានការប្រែប្រួលអាកាសធាតុយ៉ាងដូចម្តេចខ្លះក្នុងតំបន់ក្បែរៗអ្នក?" តារាងនៅក្នុងស្លាយទី ៥ ។

**កិច្ចសហការដែលអាចមានជាមួយអ្នកដទៃ**

ព័ត៌មានដែលសិស្សានុសិស្សបានប្រមូលជាផ្នែកនៃកិច្ចការផ្ទះនេះ អាចបានចែករំលែកជាមួយដៃគូមកពីសាលារៀននៅក្នុងតំបន់ ឬប្រទេសផ្សេងទៀត។

## ផ្នែកទី ២៖ តើវិបត្តិអាកាសធាតុជះឥទ្ធិពលយ៉ាងណាខ្លះទៅលើមនុស្សខុសៗគ្នា ?

- ចូរយកទឹកមួយកែវ និងក្រដាសមួយសន្លឹក។ សួរសិស្សានុសិស្សថាតើនឹងមានអ្វីកើតឡើង ប្រសិនបើអ្នកចាក់ទឹកលើអ្វីមួយ។ ប្រតិកម្មទូទៅគឺថាវត្ថុនោះនឹងសើម។ ឥលូវសួរគេថា តើនឹងមានអ្វីកើតឡើងបើអ្នកចាក់ទឹកលើដី។ តើវានឹងប៉ះពាល់ក្រដាសដោយរបៀបណា ? វានឹងមិនប៉ះពាល់ទេ។ ទោះជាយ៉ាងណាក៏ដោយប្រសិនបើដាក់ក្រដាសនៅលើដីដែលមានទឹកសើមនោះ ក្រដាសនឹងសើមហើយជោគជាំដែរ។ ចូរពន្យល់ថានេះជាអ្វីដែល "ការប៉ះពាល់ជាក់ស្តែង" ស្ថិតនៅក្នុងកន្លែងដែលឱកាសនៃការប៉ះផ្ទាល់ជាមួយនឹងសញ្ញាគ្រោះថ្នាក់ ( ឬគ្រោះថ្នាក់ ) មានកម្រិតខ្ពស់។

- បង្ហាញសិស្សានុសិស្សនូវក្រដាសកាតុង ហើយសួរពួកគេថាតើនឹងមានអ្វីកើតឡើង ប្រសិនបើអ្នកចាក់ទឹកលើក្រដាស និងក្រដាសកាតុង។ ប្រតិកម្មគឺថាក្រដាសទាំងពីរនឹងសើម។ ប៉ុន្តែតើក្រដាសកាតុងនឹងសើមជោគកម្រិតណា គឺអាស្រ័យលើបរិមាណទឹកដែលបានចាក់ ទឹកតិចពេកនឹងមិនធ្វើឲ្យខ្ទេចក្រដាសកាតុងទេ ប៉ុន្តែវានឹងធ្វើឲ្យក្រដាសធម្មតាខ្ទេចបាន។ ពន្យល់ថានេះគឺជា "ភាពងាយរងគ្រោះ" កម្រិតនៃភាពងាយស្រួលរងគ្រោះថ្នាក់។ ជារឿយៗភាពងាយរងគ្រោះ ក៏ផ្អែកលើបរិមាណនៃការប៉ះពាល់ជាក់ស្តែងផងដែរ។ [ប្រភពសកម្មភាព៖ ព្រួញ]

- បង្ហាញស្លាយទី ៦ ដើម្បីបណ្តុះគំនិតដែលថាផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុអាស្រ័យទៅលើកម្រិតនៃការប៉ះពាល់ជាក់ស្តែង និងភាពងាយរងគ្រោះរបស់អ្នកដែលរងគ្រោះនោះ ( ហានិភ័យនៃគ្រោះថ្នាក់ ដ្យាក្រាម Venn ) ហើយបន្ទាប់មកទស្សនាផែនទីអន្តរកម្មសន្ទស្សន៍ហានិភ័យអាកាសធាតុរបស់កុមារ ( ចំណុចនេះដំណើរការល្អតាមរយៈការស្វែងរកតាមគេហទំព័រក្នុងអ៊ីនធើណិតមួយចំនួនប្រសើរជាងកម្មវិធីផ្សេងទៀត )។

https://experience.arcgis.com/experience/0d9d2209bf104584a65e012b03b6d3f8/?data_id=dataSource_2-17b3a7be4c5-layer-1_427%3A217

ផែនទីទីមួយ (ក៏មាននៅលើស្លាយទី ៧ ផងដែរ) និងក្រឡានតារាងបង្ហាញពីកម្រិតហានិភ័យចំពោះកុមារនៅក្នុងផ្នែកផ្សេងៗនៅពិភពលោកនៃផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ (ផែនទីពីរផ្សេងទៀតបង្ហាញពីសមាសធាតុនៃសន្ទស្សន៍ហានិភ័យនេះ៖ ផែនទី និងក្រឡានតារាងទីពីរបង្ហាញពីភាពធ្ងន់ធ្ងរនៃការប៉ះពាល់ជាក់ស្តែង, និងទីបីកម្រិតនៃភាពងាយរងគ្រោះ។) សូមសួរសិស្សានុសិស្សថាតើពួកគេសម្គាល់ឃើញលំនាំណាមួយនៅក្នុងផែនទីពិភពលោកដែរឬទេ។ តើកុមារក្នុងផ្នែកណាខ្លះនៃពិភពលោកដែលមានហានិភ័យខ្ពស់បំផុត? សិស្សានុសិស្សក៏អាចប្រើផែនទីអន្តរកម្ម ដើម្បីស្វែងរកកម្រិតហានិភ័យនៅក្នុងប្រទេសខ្លួន/ប្រទេសដទៃទៀតផងដែរ។

- សួរសិស្សានុសិស្សថាតើកត្តាអ្វីខ្លះដែលអាចធ្វើឱ្យកន្លែងខ្លះងាយរងគ្រោះជាងកន្លែងផ្សេងទៀតនៅក្នុងប្រទេសទាំងនេះ។

សម្រាប់ការប៉ះពាល់ជាក់ស្តែង (សសរស្តម្ភទី១) សន្ទស្សន៍ CCRI ប្រើប្រាស់កត្តាដូចជា កង្វះទឹក ហានិភ័យជំនន់តាមមាត់សមុទ្រ ការប៉ះពាល់ជាក់ស្តែងនឹងខ្យល់ត្រូពិក ជំងឺឆ្លងតាមភ្នាក់ងារចម្លង (ឧទាហរណ៍ ជំងឺគ្រុនចាញ់ និងគ្រុនឈាម) និងការបំពុលដី និងទឹក។ ចំពោះភាពងាយរងគ្រោះ (សសរស្តម្ភទី២) សន្ទស្សន៍ CCRI ប្រើកត្តាដូចជាសុខភាព និងអាហារូបត្ថម្ភរបស់កុមារ។ ការអប់រំ ទឹកស្អាត និងអនាម័យ និងភាពក្រីក្រ ទ្រព្យប្រាស្រ័យទាក់ទង និងកិច្ចគាំពារសង្គម។[7]

### ផ្នែកទី ៣៖ តើមានវិធីអ្វីខ្លះដើម្បីដោះស្រាយមូលហេតុនៃការប្រែប្រួលអាកាសធាតុ?

- សុំឲ្យសិស្សានុសិស្សផ្តល់ជាដំណោះស្រាយដែលអាចមានចំពោះការប្រែប្រួលអាកាសធាតុ។ សរសេរដំណោះស្រាយទាំងនោះនៅលើក្តារខៀន ហើយចែកចេញជាបីប្រភេទ៖

  ១. ដំណោះស្រាយបច្ចេកទេស (ដែលផ្តោតជាសំខាន់លើការកាត់បន្ថយការបំភាយឧស្ម័នដោយមធ្យោបាយបច្ចេកទេស)

  ២. ដំណោះស្រាយឥរិយាបថ (ដែលផ្តោតជាសំខាន់លើការផ្លាស់ប្តូរឥរិយាបថ) និងប្រព័ន្ធសង្គម និងសេដ្ឋកិច្ច)

  ៣. ដំណោះស្រាយពាសពេញប្រព័ន្ធទាំងមូល (ដែលផ្តោតលើការផ្លាស់ប្តូរប្រព័ន្ធសេដ្ឋកិច្ច និងប្រព័ន្ធទាំងមូល)។

  ដំណោះស្រាយមួយចំនួនអាចត្រូវលើសពីមួយប្រភេទ។

- បន្ទាប់មកបង្ហាញវីដេអូ David Attenborough "តើជួយសង្គ្រោះភពផែនដីរបស់យើងតាមវិធីណា" (ស្លាយទី ៨)
  https://www.ourplanet.com/en/
  https://www.youtube.com/watch?v=0Puv0Pss33M
  (© WWF, Netflix and Silverback Films ៨ នាទី ២៧ វិនាទី។

វីដេអូនេះរួមបញ្ចូលដំណោះស្រាយសំខាន់ៗចំនួនបួន៖

១. ឈប់ប្រើឥន្ធនៈយកពីក្រោមដី

២. ផលិតកម្មស្បៀងអាហារសន្សំសំចៃជាងមុន (រួមទាំងការបរិភោគសាច់តិចជាងមុន)

៣. គ្រប់គ្រងមហាសមុទ្រ

៤. ដាំដើមឈើឲ្យក្លាយជាព្រៃឡើងវិញតាមទំហំដីដែលអាចធ្វើទៅបាន និងលើកទឹកចិត្តការពារធម្មជាតិ។

សួរសិស្សានុសិស្សថាតើចំណុចមួយណាគួរស្ថិតនៅក្រោម "ដំណោះស្រាយបច្ចេកទេស" និងចំណុចមួយណានៅក្រោម "ដំណោះស្រាយឥរិយាបថ" ឬ "ដំណោះស្រាយពាសពេញប្រព័ន្ធ"។

#### កិច្ចសហការដែលអាចមានជាមួយអ្នកដទៃ

ដំណោះស្រាយដែលសិស្សានុសិស្សបានស្នើឡើងចំពោះការប្រែប្រួលអាកាសធាតុ អាចចែករំលែកជាមួយដៃគូពីសាលារៀននៅក្នុងតំបន់ ឬប្រទេសផ្សេងទៀត។

## សកម្មភាពបន្ថែម

សូមណែនាំឲ្យស្គាល់ការបង្ហាញគ្រាប់អំពីដំណោះស្រាយការប្រែប្រួលអាកាសធាតុនៅលើគេហទំព័រ https://www.climateinteractive.org/ ។ (ស្លាយទី ៩) ចូលទៅកាន់ម៉ឺនុយ "ជំនួយ" ហើយជ្រើសរើស "ឧទាហរណ៍ដែលពាក់ព័ន្ធ" ដើម្បីយល់ពីស្លាយកាន់តែច្បាស់ (បិទប្រអប់ដើម្បីបង្ហាញស្លាយម្តងទៀត)។

កំណត់ដំណោះស្រាយដែលបានស្នើនៅក្នុងវីដេអូ ហើយផ្លាស់ទីស្លាយដែលសមស្របទៅខាងឆ្វេង (ធ្យូងថ្ម, ប្រេង, ឧស្ម័នធម្មជាតិ, ជីវថាមពល, ការកាប់ព្រៃឈើ, មេតាន, និងផ្សេងទៀត) ឬទៅខាងស្តាំ (អ្វីដែលកកើតឡើងវិញ និងការដាំព្រៃឈើឡើងវិញ)។ បន្ទាប់មកកំណត់ដំណោះស្រាយបន្ថែមទៀតដែលសិស្សានុសិស្សអាចស្នើពីបញ្ជីស្លាយ ឬឧទាហរណ៍ដែលពាក់ព័ន្ធ ហើយផ្លាស់ទីស្លាយដើម្បីមើលផលប៉ះពាល់អំពីការបំភាយឧស្ម័នកាបូនិក។ ឲ្យសិស្សានុសិស្សណែនាំស្លាយផ្សេងទៀតដើម្បីផ្លាស់ទី (ឬព្យាយាមផ្លាស់ទីស្លាយទាំងនោះដោយខ្លួនគេផ្ទាល់)។ តើសិស្សានុសិស្សមានកត់សម្គាល់ឃើញអ្វីខ្លះ? តើវិធានការមួយណាទំនងជាមានផលជះខ្លាំងបំផុតក្នុងការកាត់បន្ថយការកើនឡើងនៃសីតុណ្ហភាព ១,៥ °C? តើវិធានការទាំងនោះជាដំណោះស្រាយផ្នែកបច្ចេកទេស ឥរិយាបថ ឬពាសពេញប្រព័ន្ធ ឬបញ្ចូលគ្នា?

[7] វិធីសាស្ត្រ CCRI ដែលមាននៅទំព័រ ១០៣ ដល់ ១០៩៖
https://www.unicef.org/esa/media/6726/file/GRP-A-Toolkit-for-Teachers-and-Schools-2020.pdf

## ការពិភាក្សាជាក្រុមនៅចុងបញ្ចប់នៃវគ្គទី ១

សួរសិស្សានុសិស្សថាតើការកាត់បន្ថយការបំភាយឧស្ម័នកាបូនិក គឺគ្រប់គ្រាន់ដើម្បីដោះស្រាយវិបត្តិដែលពាក់ព័ន្ធនឹងអាកាសធាតុដែរឬទេ? លើកទឹកចិត្តឲ្យមានការពិភាក្សាដែលវាយតម្លៃថាដំណោះស្រាយបច្ចេកទេស និងឥរិយាបថមានសារៈសំខាន់ ដើម្បីធ្វើការរួមជាមួយនឹងការទទួលស្គាល់ដំណោះស្រាយពាសពេញប្រព័ន្ធ ដែលបង្កើតភាពធន់នៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ជាពិសេសសម្រាប់អ្នកដែលប្រឈមបំផុតពីការប្រែប្រួលអាកាសធាតុ។ នេះគ្រាន់តែដើម្បីពិនិត្យមើលថាតើសិស្សានុសិស្សចាប់ផ្តើមផ្តល់តម្លៃថាគេមានវិធីផ្សេងៗដែលអាចវាស់វែង និងដោះស្រាយបញ្ហាបំភាយឧស្ម័ន ការប៉ះពាល់ជាក់ស្តែងនឹងអាកាសធាតុ និងភាពងាយរងគ្រោះបាន។

# ជំហានទី ២៖ យុត្តិធម៌អាកាសធាតុ

## គោលបំណងសិក្សា

នៅចុងបញ្ចប់នៃវគ្គនេះ សិស្សានុសិស្សនឹង៖

- អាចគូសបញ្ជាក់អំពីអំណះអំណាងដែលថាគេគួរចែករំលែកបន្ទុកទទួលខុសត្រូវ ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុរវាងប្រទេសនានាដោយរបៀបណា
- មានការយល់ដឹងកាន់តែច្រើនអំពីថាតើសកម្មភាពទាំងឡាយ ដើម្បីបង្ការទប់ស្កាត់ ឬឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុមិនគួរបង្កគ្រោះថ្នាក់ ឬផាត់ចេញបុគ្គល ឬក្រុមណាមួយឡើយ ហើយផ្ទុយទៅវិញគួរតែជួយដោះស្រាយវិសមភាពដែលការប្រែប្រួលអាកាសធាតុបានបង្កឡើង ឬកាន់តែអាក្រក់ទៅៗយ៉ាងដូចម្តេចខ្លះ។

## សេចក្តីផ្តើមទៅនឹងទស្សនទានយុត្តិធម៌អាកាសធាតុ

- ណែនាំឲ្យស្គាល់អំពីទស្សនទាននៃយុត្តិធម៌អាកាសធាតុ។ សួរសិស្សានុសិស្សថាតើពួកគេគិតថា "យុត្តិធម៌អាកាសធាតុ" មានន័យដូចម្តេច? មាននិយមន័យ (នៅលើស្លាយទី ១០) ត្រៀមខ្លួនជាស្រេចដើម្បីចែករំលែក៖ "យុត្តិធម៌អាកាសធាតុមានទំនាក់ទំនងទៅនឹងសិទ្ធិមនុស្ស និងការអភិវឌ្ឍ ដើម្បីសម្រេចបាននូវអភិក្រមមនុស្សមជ្ឈមណ្ឌល ការការពារសិទ្ធិជនងាយរងគ្រោះបំផុត, និងការចែករំលែកបន្ទុក និងអត្ថប្រយោជន៍នៃការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ដោយសមធម៌ និងស្មើភាព។"[8]

  ផ្នែកសំខាន់មួយនៃយុត្តិធម៌អាកាសធាតុ គឺការទទួលស្គាល់ថាការប្រែប្រួលអាកាសធាតុមានឥទ្ធិពលលើស្ត្រី និងបុរសខុសៗគ្នា។ នៅក្នុងបរិបទដែលមានវិសមភាពយេនឌ័រ និងកម្រិតនៃភាពក្រីក្រខ្ពស់ ស្ត្រី និងកុមារីទទួលបន្ទុកកាន់តែធ្ងន់ធ្ងរពីវិបត្តិអាកាសធាតុ (ស្លាយទី ១០)។

- វគ្គនេះនឹងពិនិត្យមើលថាតើអ្នកណាជាអ្នកទទួលខុសត្រូវចំពោះការបំភាយឧស្ម័ន និងរបៀបដែលប្រទេសនានាអាចចែករំលែកបន្ទុកនេះតាមរយៈការចូលរួមជាមួយគោលការណ៍ ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដែលគោរពតាមសេចក្តីត្រូវការដើម្បីភាពត្រឹមត្រូវ សមធម៌ និងយុត្តិធម៌។

- ឲ្យសិស្សានុសិស្សធ្វើការជាគូ ឬជាក្រុមតូចៗ ដើម្បីពិភាក្សាសំណួរ "តើប្រទេសណាដែលទទួលខុសត្រូវចំពោះ ការប្រែប្រួលអាកាសធាតុជាងគេ?" អ្នកអាចផ្តល់បញ្ជីប្រទេស និងទីបដែលត្រូវដាក់ទៅតាមចំណាត់ថ្នាក់ ឧទាហរណ៍៖ ចិន ឥណ្ឌា អេត្យូពី អារ៉ាប៊ីសាអូឌីត វៀតណាម អឺរ៉ុប អាហ្វ្រិកខាងត្បូង សហរដ្ឋអាមេរិក ប្រេស៊ីល អូស្ត្រាលី សហព័ន្ធរុស្ស៊ី អ៊ីរ៉ង់ ហ្វ៊ីនឡែន កាតា ជប៉ុន ម៉ាលី។

- ផ្តល់សន្លឹកកិច្ចការជំហានទី ២ ហើយសុំឲ្យសិស្សានុសិស្សអានតាមរយៈអំណះអំណាង ហើយមើលក្រាភិកលើស្លាយ (ដែលមាននៅលើស្លាយទី ១១ ដល់ ១៦)។ ចំពោះអំណះអំណាងនីមួយៗ សិស្សានុសិស្សគួរតែសម្រេចចិត្តថាតើពួកគេយល់ស្រប មិនយល់ស្រប ឬមិនប្រាកដ ហើយសរសេរចម្លើយរបស់សិស្សានុសិស្សលើក្តារ ខៀន។ វាជារឿងសំខាន់ដែលសិស្សានុសិស្សបានពិនិត្យមើលចម្លើយរបស់ខ្លួនម្តងទៀតនៅចុងបញ្ចប់ ហើយកែតម្រូវចម្លើយទាំងនោះ ប្រសិនបើសិស្សានុសិស្សប្តូរចិត្តលើចម្លើយណាមួយ។ ជាចុងក្រោយ សិស្សានុសិស្សគួរតែអានការបកស្រាយនៅខាងក្រោមសន្លឹកកិច្ចការ។

[8] ដកស្រង់ចេញពីគេហទំព័រយុត្តិធម៌អាកាសធាតុរបស់មូលនិធិ Mary Robinson៖ https://www.mrfcj.org/principles-of-climate-justice/

# ផ្នែកទី ១៖ តើអ្នកណាជាអ្នកទទួលខុសត្រូវចំពោះការប្រែប្រួលអាកាសធាតុ?

## សន្លឹកកិច្ចការ

- សូមអានអំណះអំណាង ១ ដល់ ៨ ខាងក្រោម ហើយមើលស្លាយទី ១២ ដល់ ១៦ ។
- ចូរសម្រេចចិត្តអំពីជំហរបស់អ្នកនៅលើបន្ទាត់យល់ស្រប/មិនយល់ស្របចំពោះអំណះអំណាងនីមួយៗ ហើយកត់ត្រាចម្លើយរបស់អ្នក។
- រកមើលចម្លើយរបស់អ្នកម្តងទៀតនៅចុងបញ្ចប់ ហើយកែតម្រូវ ប្រសិនបើអ្នកត្រូវការ។
- ពិនិត្យចម្លើយរបស់អ្នក ហើយអានការបកស្រាយ។

មិនយល់ស្រប — មិនប្រាកដ — យល់ស្រប

១. ប្រទេសចិនបញ្ចេញឧស្ម័នកាបូនិកជិត ៣០ ភាគរយនៃការបំភាយឧស្ម័នពិភពលោកសរុប។ ចំណុចនេះគឺច្រើនជាងប្រទេសដទៃទៀត។ ចិនមានការទទួលខុសត្រូវខ្ពស់ជាងគេក្នុងការដោះស្រាយការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់។ (ក្រាភិក ក ស្លាយទី ១២)

២. ប្រទេសដែលផលិតប្រេងគឺប្រទេសកាតា ដែលបំភាយឧស្ម័នកាបូនិក ខ្ពស់បំផុតក្នុងមនុស្សម្នាក់។ កាតាមានការទទួលខុសត្រូវខ្ពស់បំផុត ក្នុងការដោះស្រាយការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់។ (ក្រាភិក ខ ស្លាយទី ១៣)

៣. ការប្រែប្រួលអាកាសធាតុភាគច្រើនបណ្តាលមកពីប្រវត្តិនៃការបំភាយឧស្ម័នកាបូនិក ក្នុងរយៈពេលប៉ុន្មានរយឆ្នាំចុងក្រោយនេះ។ ឧស្ម័នកាបូនិក ស្ថិតនៅក្នុងបរិយាកាសរយៈពេលយូរ។ រហូតមកដល់ពេលនេះ សហរដ្ឋអាមេរិក និងអឺរ៉ុបបានបញ្ចេញឧស្ម័នកាបូនិកច្រើនបំផុត ចាប់តាំងពីឆ្នាំ ១៧៥១ (ការចាប់ផ្តើមនៃបដិវត្តន៍ឧស្សាហកម្ម)។ ប្រទេសទាំងនេះមានការទទួលខុសត្រូវខ្ពស់បំផុតក្នុងការដោះស្រាយការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់។ (ក្រាភិក គ ស្លាយទី ១៤)

៤. ប្រជាជនដែលរស់នៅក្នុងសហរដ្ឋអាមេរិក និងអឺរ៉ុប កាលពី ២០០ ឆ្នាំមុន មិនបានដឹងថាអ្វីដែលពួកគេកំពុងធ្វើនឹងបង្កឲ្យមានការប្រែប្រួលអាកាសធាតុនោះទេ ហើយយ៉ាងណាក៏ដោយឥលូវនេះពួកគេបានលាចាកលោកទៅហើយ។ កូនចៅរបស់ពួកគេមិនមានការទទួលខុសត្រូវខ្ពស់បំផុតក្នុងការដោះស្រាយការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់នោះទេ។

៥. កូនចៅរបស់ប្រជាជនមកពីប្រទេសដែលបញ្ចេញឧស្ម័នកាបូនិកច្រើនបំផុតតាមប្រវត្តិសាស្ត្រ បានទទួលអត្ថប្រយោជន៍ពីកម្រិតជីវភាពរស់នៅខ្ពស់ ដែលអាចធ្វើទៅបានតាមរយៈការដុតឥន្ធនៈយកពីក្រោមដីក្នុងរយៈពេលរាប់រយឆ្នាំមកនេះ។ ពួកគេមានការទទួលខុសត្រូវខ្ពស់បំផុតក្នុងការដោះស្រាយការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់។ (ក្រាភិក ឃ ស្លាយទី ១៥)

៦. ការចំណាយលើការដោះស្រាយការប្រែប្រួលអាកាសធាតុ និងការខាតបង់ និងការខូចខាតដែលបង្កឡើងនៅទូទាំងពិភពលោក គឺថ្លៃពេកសម្រាប់សហរដ្ឋអាមេរិក អឺរ៉ុប និងប្រទេសមួយចំនួនទៀតដែលទទួលខុសត្រូវបំផុតដែលត្រូវទូទាត់សង។

៧. ប្រជាជន ៥០ ភាគរយដែលក្រីក្របំផុតនៅលើពិភពលោក ទទួលខុសត្រូវចំពោះការបំភាយឧស្ម័នប្រហែល ១០ ភាគរយ ប៉ុន្តែត្រូវទទួលបន្ទុកដ៏ធំបំផុតនៅពេលនិយាយអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ភាគច្រើននៃ ប្រជាជនទាំងនេះរស់នៅក្នុងភាគខាងត្បូងពិភពលោក។ ដូច្នេះ បណ្តាប្រទេសនៅភាគខាងត្បូងពិភពលោក គួរតែទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសពីប្រទេសអ្នកមាន នៅពេលនិយាយអំពីសកម្មភាពកាត់បន្ថយ និងបន្សាំអាកាសធាតុ។ (ក្រាភិក ង ស្លាយទី ១៦)

៨. ភាគច្រើននៃកុមារីនៅលើពិភពលោកទំនងជាជួបប្រទះផលប៉ះពាល់អវិជ្ជមានចំពោះការអប់រំ និងសុខភាពរបស់ខ្លួន ដែលរស់នៅក្នុងប្រទេសដែលងាយរងគ្រោះអាកាសធាតុនៅក្នុងភាគខាងត្បូងនៃពិភពលោក។ លទ្ធផលអប់រំរបស់កុមារីទាំងនេះមានហានិភ័យរួចទៅហើយ ដោយសារតែបទដ្ឋានយេនឌ័រដែលបង្កគ្រោះថ្នាក់ (ឧទាហរណ៍ អាពាហ៍ពិពាហ៍ក្មេងវ័យ និងដោយបង្ខំ) និងវិសមភាពយេនឌ័រដែលបណ្តាលឲ្យមានភាពក្រីក្របន្តពីមួយជំនាន់ទៅមួយជំនាន់។ ប្រទេសដែលការអប់រំរបស់កុមារីប្រឈមនឹងហានិភ័យបំផុតពីផលប៉ះពាល់អាកាសធាតុ គួរតែត្រូវបានគាំទ្រ ដើម្បីកែលម្អសមធម៌ និងសមភាពនៃការអប់រំ។

## ពិនិត្យចម្លើយរបស់អ្នក

ប្រសិនបើអ្នកយល់ស្របជាមួយអំណះអំណាងទី ១ ២ ៤ និង ៦ ហើយមិនយល់ស្របជាមួយ ៣ ៥ ៧ និង ៨ អ្នកទំនងជាត្រូវបានបន្សុីគ្នាជាមួយអ្នកចរចានៅភាគខាងជើងនៃពិភពលោក (ឧទាហរណ៍៖ សហរដ្ឋអាមេរិក និងអឺរ៉ុប)។

ប្រសិនបើអ្នកយល់ស្របជាមួយអំណះអំណាងទី ៣ ៥ ៧ និង ៨ ហើយមិនយល់ស្របជាមួយ ១ ២ ៤ និង ៦ អ្នកទំនងជាត្រូវបានបន្សុីគ្នាជាមួយអ្នកចរចានៅភាគខាងត្បូងពិភពលោក (ឧទាហរណ៍៖ ប្រជាជាតិនៃអាសុីខាងត្បូង ឬអាហ្វ្រិក) ទោះបីជាអ្នកខ្លះក៏យល់ស្របជាមួយនឹងអំណះអំណាងទី ១ ក៏ដោយ។

ជំហរខុសៗគ្នាទាំងនេះ គឺជាឧបសគ្គដ៏សំខាន់មួយ ដែលកំពុងរារាំងប្រទេសនានាក្នុងពិភពលោកពីការយល់ស្របលើសកម្មភាពកាន់តែខ្លាំង ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់។ ឧទាហរណ៍ អ្នកចរចាមកពីប្រទេសជាច្រើននៃភាគខាងត្បូងពិភពលោកនិយាយថាខ្លួនមិនអាចឈប់បំភាយឧស្ម័នកាបូនិក ឬប្រេងឥន្ធនៈយកពីក្រោមដីទៅជាថាមពលកកើតឡើងវិញ និងការពារបរិស្ថានបានទេ លុះត្រាតែខ្លួនទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុដើម្បីធ្វើដូច្នេះ។ រដ្ឋាភិបាលមកពីប្រទេសជាច្រើននៃភាគខាងជើងពិភពលោក មានការស្ទាក់ស្ទើរក្នុងការទូទាត់ចំនួនទឹកប្រាក់ដែលត្រូវការ។ អ្នកចរចាមកពីប្រទេសជាច្រើននៃភាគខាងត្បូងពិភពលោក ក៏និយាយដែរថាខ្លួនទទួលខុសត្រូវតិចតួចបំផុតចំពោះការប្រែប្រួលអាកាសធាតុ ប៉ុន្តែជាអ្នកកំពុងទទួលឥទ្ធិពលអាក្រក់បំផុត។ តើអ្នកគិតថាគួរមានអ្វីកើតឡើង ?

ការចរចាអំពីការប្រែប្រួលអាកាសធាតុកើតឡើងរវាងប្រទេសនានា ប៉ុន្តែអ្នកមានបំផុត ១០ ភាគរយនៃប្រជាជនលើពិភពលោក បញ្ចេញស្ទើរតែពាក់កណ្ដាលនៃការបំភាយឧស្ម័នកាបូនិកសរុប ពាក់ព័ន្ធនឹងរបៀបរស់នៅ (ក្រាភិក ង, ស្លាយទី ១៦) ។ តើចំណុចនេះគួរតែយកទៅពិចារណាដែរឬទេ ?

## ផ្នែកទី ២៖ តើសមភាព សមធម៌ និងយុត្តិធម៌មានទំនាក់ទំនងនឹងការប្រែប្រួលអាកាសធាតុយ៉ាងដូចម្ដេចខ្លះ ?

ដើម្បីដោះស្រាយបញ្ហាអយុត្តិធម៌អាកាសធាតុទាំងនេះ ប្រទេសចំនួន ១៩៧ បានប្រមូលផ្ដុំគ្នានៅក្នុងឆ្នាំ ២០១៥ ដើម្បីបង្កើតកិច្ចព្រមព្រៀងទីក្រុងប៉ារីស ដែលមានគោលដៅសំខាន់ៗចំនួនបី៖

១. សម្រាប់ប្រទេសនានា ដើម្បីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់របស់ខ្លួន។

២. ដើម្បីបញ្ឈប់ការកើនឡើងនៃសីតុណ្ហភាពសកលជាមធ្យម ១,៥ អង្សាសេនៅឆ្នាំ ២០៥០

៣. ដើម្បីជួយមនុស្ស និងភពផែនដី គ្រប់គ្រងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។[9]

កិច្ចព្រមព្រៀងទីក្រុងប៉ារីស ប្រាប់ថ្នាក់ដឹកនាំប្រទេសទាំងឡាយឲ្យដាក់បញ្ចូលយុវជនក្នុងការសម្រេចចិត្តអំពីអាកាសធាតុ ហើយត្រូវប្រាកដថាសកម្មភាពដែលបានធ្វើឡើងគឺយុត្តិធម៌ និងសមធម៌។ នេះមានន័យថាសកម្មភាពទាំងឡាយណាដើម្បីបង្ការទប់ស្កាត់ ឬឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ មិនគួរបង្កគ្រោះថ្នាក់ ឬផាត់ចេញបុគ្គល ឬក្រុមណាមួយឡើយ ហើយផ្ទុយទៅវិញ គួរតែជួយដោះស្រាយវិសមភាពដែលការប្រែប្រួលអាកាសធាតុបានបង្កឡើង ឬធ្វើឲ្យកាន់តែអាក្រក់ទៅៗ។

## សេចក្ដីផ្ដើមទៅនឹងទស្សនទាននៃវិសមភាព, យុត្តិធម៌, សមធម៌, ការរំដោះ (យុត្តិធម៌)

បង្ហាញសិស្សានុសិស្សនូវរូបភាពខាងក្រោម (និងនៅលើស្លាយទី ១៧) ហើយពន្យល់និយមន័យ៖

- **សមភាព** (ឬភាពស្មើភាពគ្នា) មានន័យថាជាការចាត់ទុកមនុស្សគ្រប់រូបស្មើៗគ្នា៖ ដូចបង្ហាញក្នុងរូបភាពដែលមនុស្សម្នាក់ៗមានដុំប្លុកមួយដើម្បីឈរពីលើ។
- **សមធម៌** មានន័យថាផ្ដល់ឲ្យមនុស្សម្នាក់ៗនូវការគាំទ្រជាក់លាក់ដែលពួកគេត្រូវការ៖ ដូចបង្ហាញក្នុងរូបភាពនៃការផ្ដល់ប្លុកបន្ថែមដល់មនុស្សទាបបំផុត។
- **ការរំដោះ** (ឬយុត្តិធម៌) មានន័យថាការដករបាំងដែលរារាំងមនុស្សពីការទទួលបាននូវអ្វីដែលខ្លួនត្រូវការក្នុងជីវិត៖ ដូចបង្ហាញក្នុងរូបភាពពីការដកចេញនៃរបងទាំងស្រុង។



[9] ភាពជាអ្នកដឹកនាំរបស់យុវជនក្នុងសៀវភៅការងារគោលនយោបាយអាកាសធាតុ និងការណែនាំរបស់អ្នកសម្របសម្រួល ជំពូកទី ១ ទំព័រទី ២ https://plan-international.org/publications/youth-leadership-climate-policy-workbook-and-facilitators-guide

ដើម្បីជំរុញឲ្យមានការយល់ដឹងបន្ថែម អ្នកអាចឲ្យសិស្សានុសិស្ស និយាយថាតើសេចក្តីថ្លែងការណ៍ខាងក្រោមមួយណាគួរស៊ីជាមួយ ឧទាហរណ៍ជារូបភាពមួយណា។

- កុមារទាំងអស់មានសិទ្ធិទទួលបានការអប់រំដោយឥតគិតថ្លៃ
- ការគាំទ្រផ្នែកអប់រំត្រូវបានផ្តល់ជូនជាភាសាកំណើតរបស់កុមារទាំងនោះដែលមិននិយាយភាសាជាតិនោះទេ
- រដ្ឋាភិបាលផ្តល់ថវិកា និងជំនួយគ្រប់គ្រាន់ដើម្បីឲ្យកុមារី និងកុមារាមកពីគ្រួសារងាយរងគ្រោះ អាចទទួលបានការអប់រំប្រកបដោយគុណភាព។




*Interaction Institute for Social Change and Center for Story-based Strategy | Artist: Angus Maguire.*

# ជំហានទី ៣៖ ការអប់រំរបស់កុមារី និងការប្រែប្រួលអាកាសធាតុ

## គោលបំណងសិក្សា

នៅចុងបញ្ចប់នៃវគ្គ សិស្សានុសិស្សនឹង៖

- ស្វែងយល់ពីរបៀបដែលគ្រោះមហន្តរាយពាក់ព័ន្ធនឹងអាកាសធាតុ ជារឿយៗពង្រីកវិសមភាពយេនឌ័រដែលមានស្រាប់ ជាពិសេសនៅក្នុងស្ថានភាពក្រីក្រ
- អាចពិភាក្សាអំពីរបៀបដែលការអប់រំរបស់កុមារីផ្តល់អត្ថប្រយោជន៍ដល់សង្គមទាំងអស់ក្នុងការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងធ្វើឲ្យសង្គមមួយមានភាពយុត្តិធម៌ និងនិរន្តរភាពជាងមុន។

## ផ្នែកទី ១៖ សេចក្តីផ្តើមទៅនឹងវិសមភាពយេនឌ័រ និងផលប៉ះពាល់នៃគ្រោះមហន្តរាយលើយេនឌ័រ

- ពន្យល់ដល់សិស្សានុសិស្សថា យើងនឹងពិនិត្យមើលវិសមភាពយេនឌ័រ។ តើពាក្យនេះមានន័យដូចម្តេច?
- សូមមើលសេណារីយ៉ូយេនឌ័រនៅលើស្លាយទី ១៨ ។ តើពួកគេគិតថានឹងមានអ្វីកើតឡើង ហើយហេតុអ្វី?

  **យោបល់៖**

  **ក – សមភាពតិចតួច៖** ការអប់រំរបស់កុមារាត្រូវបានគេមើលឃើញថាជាទ្រព្យសម្បត្តិដ៏ច្រើននៅក្នុងគ្រួសារមួយចំនួន។ គេរំពឹងថាកុមារានឹងទទួលបានការងារដើម្បីទ្រទ្រង់គ្រួសាររបស់ខ្លួននៅពេលដែលកុមារាធំធាត់ និងមានគ្រួសារ។ ការវិនិយោគលើការអប់រំរបស់កុមារីត្រូវបានគេមើលឃើញថាជាការវិនិយោគមិនល្អ ដោយសារតែកុមារីទំនងជាមានការទទួលខុសត្រូវលើកិច្ចការក្នុងផ្ទះច្រើនជាង ទើបពុំមានពេលវេលាធ្វើការងារទទួលបានប្រាក់ឈ្នួល។ កុមារីក៏ទំនងជារៀបអាពាហ៍ពិពាហ៍ក្នុងវ័យជំទង់ដែរ ដូច្នេះគ្រួសាររបស់នាងផ្ទាល់នឹងមិនទទួលបានអត្ថប្រយោជន៍ពីប្រាក់ចំណូលណាមួយដែលនាងអាចរកបានពីការងារនោះទេ។ នៅក្នុងការកំណត់អាកប្បកិរិយាទាំងនេះចំពោះតួនាទីយេនឌ័រ គ្រួសារដែលមានធនធានមានកម្រិតតែងតែផ្តល់អាទិភាពដល់ការអប់រំរបស់កុមារា ខណៈដែលកុមារីត្រូវស្នាក់នៅផ្ទះដើម្បីជួយការងារផ្ទះ និងមើលថែទាំប្អូនៗ។

  **ក – សមភាពច្រើន៖** ឪពុកម្តាយនឹងទទួលស្គាល់ថាកូនរបស់ខ្លួនទាំងអស់មានសិទ្ធិស្មើគ្នាក្នុងការអប់រំ ហើយកុមារា និងឪពុករបស់គាត់នឹងជួយមើលថែទាំកុមារ និងការងារផ្ទះ។ សមត្ថភាពរបស់នាងនៅផ្នែកគណិតវិទ្យាអាចនាំឲ្យមានការងារដែលទទួលបានប្រាក់ខែខ្ពស់។

  **ខ – សមភាពតិចតួច៖** ក្រុមប្រឹក្សានៅមូលដ្ឋានភាគច្រើនសម្បូរទៅដោយបុរស ហើយពួកគេមិនគិតថាស្ត្រីវ័យក្មេងមានសមត្ថភាពបច្ចេកទេសច្រើនទេ។ កុមារីត្រូវបានផាត់ចេញពីវេទិកាធ្វើការសម្រេចចិត្តនៅមូលដ្ឋាន ដោយសារអាយុ និងយេនឌ័ររបស់ខ្លួន។

  **ខ – សមភាពច្រើន៖** ក្រុមប្រឹក្សានៅមូលដ្ឋានទទួលស្គាល់ពីតម្រូវការក្នុងការចូលរួមគ្រប់វិស័យនៃសហគមន៍ ហើយថាវាមានប្រយោជន៍ ដើម្បីឲ្យយុវជនចែករំលែកគំនិតអំពីការធ្វើឲ្យមានការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ពួកគេគោរពចំណេះដឹងបច្ចេកទេស និងសមត្ថភាពរៀបចំរបស់យុវតីទាំងនេះ។

- សូមមើលស្លាយទី ១៩ ។ តើចំណុចនេះជួយពន្យល់ពីវិសមភាពយេនឌ័រយ៉ាងដូចម្តេចខ្លះ? បទដ្ឋានសង្គម (ឥរិយាបថដែលទទួលយកក្នុងចំណោមក្រុមមនុស្ស) អាចឆ្លុះបញ្ចាំង, អនុញ្ញាត, ឬនាំឲ្យមានអតុល្យភាពនៃទំនាក់ទំនងអំណាចរវាងកុមារា និងកុមារី (ដែលសិទ្ធិរបស់កុមារ ដូចជាសិទ្ធិទទួលបានការអប់រំ មិនទទួលបានភាពស្មើៗគ្នា)។ បទដ្ឋានសង្គមក៏អាចគាំទ្រដល់តួនាទីយេនឌ័រដែលមានលក្ខណៈជម្មតា (ដូចជាការថែទាំកុមារ) ដែលពង្រឹងអតុល្យភាពអំណាច និងបណ្តាលឲ្យមានវិសមភាពយេនឌ័រ លុះត្រាតែបទដ្ឋានសង្គមបែបនេះត្រូវបានគេលាតត្រដាងចេញ និងធ្វើការជំទាស់។
- តើកត្តាទាំងនេះនៅក្នុងវិសមភាពយេនឌ័រអាចជះឥទ្ធិពលលើសេណារីយ៉ូទាំងនេះយ៉ាងដូចម្តេចខ្លះ? តើកត្តាទាំងនេះនឹងមានសភាពយ៉ាងដូចម្តេចនៅក្នុងសង្គមដែលមានសមភាពតិច និងសមភាពច្រើន?
- ឧទាហរណ៍ថាមានគ្រោះមហន្តរាយមួយបានកើតឡើងនៅក្នុងបរិបទដែលមានកម្រិតក្រីក្រខ្ពស់ និងតួនាទីយេនឌ័របែបចាស់គំរិលខ្លាំង។ (លោកគ្រូអ្នកគ្រូក៏អាចប្រើឧទាហរណ៍ពីប្រទេសរបស់ខ្លួនឯងក៏បាន) អ្នកអាចលើកទឹកចិត្តឲ្យមានឧទាហរណ៍មួយចំនួនពីសិស្សានុសិស្សក្នុងថ្នាក់រៀនដើម្បីបង្ហាញពីអ្វីដែលជា "តួនាទីយេនឌ័របែបចាស់គំរិល" នោះគឺជាអ្វីដើម្បីឲ្យប្រាកដថាសិស្សានុសិស្សទាំងអស់បានយល់ថាតួនាទីទាំងនេះគឺជាអ្វីក្នុងបរិបទដែលខ្លួនកំពុងស្រមើស្រមៃ។

- ពន្យល់ថានៅក្នុងគ្រាមានវិបត្តិ តួនាទីទាំងនេះជារឿយៗមានសភាពកាន់តែច្បាស់នៅពេលដែលសហគមន៍ត្រលប់ទៅរកភាពចាស់គំរិល និងការអនុវត្តដែលមនុស្សជំនាន់មុនធ្លាប់ប្រើ។ ជាឧទាហរណ៍ ស្រ្តីប្រហែលជាបានចាប់ផ្តើមធ្វើអាជីវកម្មផ្ទាល់ខ្លួន ហើយកុមារីបានចាប់ផ្តើមចូលរៀននៅសកលវិទ្យាល័យ ប៉ុន្តែក្នុងករណីមានអាសន្ន ពួកគេតែងតែត្រលប់ទៅតួនាទីយេនឌ័របែបចាស់គំរិលដែលស្រ្តី និងកុមារីមានការទទួលខុសត្រូវមើលថែគ្រួសារ និងផ្ទះសម្បែងវិញ។
- សូមមើលសន្លឹកកិច្ចការជំហានទី ៣ (ស្លាយទី ២០)។ ទាំងនេះគឺជាបញ្ហាមួយចំនួនដែលអាចកើតឡើង ដែលជាលទ្ធផលនៃគ្រោះមហន្តរាយ និងវិបត្តិនានា។
- ឲ្យសិស្សានុសិស្សធ្វើការជាក្រុម ដើម្បីសម្រេចចិត្តថាតើបញ្ហាដែលជារឿយៗជះឥទ្ធិពលលើកុមារា ឬកុមារី ឬលើទាំងពីរភេទ ហើយចូរពន្យល់ពីមូលហេតុ។

## ជំហានទី ៣៖ បញ្ហាដែលបណ្តាលមកពីគ្រោះមហន្តរាយ និងវិបត្តិ

### សន្លឹកកិច្ចការ

| បញ្ហា | តើអ្នកណារងផលប៉ះពាល់ខ្លាំងជាងគេ? កុមារា/កុមារី/ទាំងពីរភេទ | ពន្យល់ពីមូលហេតុ? |
|---|---|---|
| កង្វះអាហារូបត្ថម្ភដោយសារគ្រួសារមួយបាត់បង់ដំណាំស្បៀង ឬចំណូលសម្រាប់ចំណាយលើអាហារ | | |
| ជំងឺឆ្លងដោយសារតែស្ថានភាពមិនមានអនាម័យ និងខ្វះទឹកពិសាសុវត្ថិភាព | | |
| បង្កើនការងារផ្ទះ និងការងារថែទាំសមាជិកគ្រួសារចាស់ជរា ឬបងប្អូនតូចៗ | | |
| ត្រូវបានគេដកចេញពីសាលាដោយសារខ្វះថវិកា | | |
| សម្ពាធកើនឡើងក្នុងការជួយរកប្រាក់ចំណូលដើម្បីផ្គត់ផ្គង់គ្រួសារ | | |
| រៀបការនៅវ័យក្មេងដើម្បីកាត់បន្ថយការប្រើប្រាស់ធនធានពីគ្រួសារ និងទទួលបានបណ្ណាការ | | |

| បញ្ហា | តើអ្នកណារងផលប៉ះពាល់ខ្លាំងជាងគេ? កុមារា/កុមារី/ទាំងពីរភេទ | ពន្យល់ពីមូលហេតុ? |
|---|---|---|
| ការធ្វើចំណាកស្រុកទៅប្រទេសផ្សេង, រស់នៅក្នុងជម្រកបណ្ដោះអាសន្ន, ឬគ្មានសុវត្ថិភាព | | |
| ការកើនឡើងនៃការប្រឈមនឹងការបៀតបៀនផ្លូវភេទ ឬអំពើហិង្សាផ្អែកលើយេនឌ័រនៅក្នុងលំនៅដ្ឋាន ឬជំរុំជនភៀសខ្លួនដែលគ្មានសុវត្ថិភាព | | |
| កង្វះនគរបាល ឬសេវាដើម្បីរាយការណ៍អំពីឧប្បត្តិហេតុនៃអំពើហិង្សាផ្លូវភេទ | | |
| ភាពតប់ប្រមល់បង្កដោយឪពុកម្ដាយ, ភាពអន្ទះសារ, និងបញ្ហាសុខភាពផ្លូវចិត្ត | | |
| ត្រូវធ្វើដំណើរឆ្ងាយជាមុន ដើម្បីយកប្រេង ឬទឹកដោយសារប្រភពត្រូវបានបំផ្លាញ ឬបំពុលដោយគ្រោះមហន្តរាយ | | |

- អានចម្លើយរបស់សិស្សនៅចំពោះមុខសិស្ស ហើយប្រៀបធៀបការពន្យល់របស់សិស្ស។ តើសិស្សានុសិស្សបានរៀនអ្វីខ្លះ? ប្រសិនបើសង្គមជាច្រើនកំពុងជួបប្រទះបញ្ហាវិសមភាពយេនឌ័ររួចហើយ តើគ្រោះមហន្តរាយ និងវិបត្តិមានផលប៉ះពាល់អ្វីខ្លះ?

### កិច្ចសហការដែលអាចមានជាមួយអ្នកដទៃ

គេអាចចែករំលែកចម្លើយរបស់សិស្សានុសិស្សនៅក្នុងសកម្មភាពនេះជាមួយថ្នាក់មកពីសាលារៀនផ្សេងនៅក្នុងតំបន់ ឬប្រទេសផ្សេងទៀត ហើយគេអាចស្វែងយល់អំពីលក្ខណៈដូចគ្នា និងខុសគ្នា។



## ផ្នែកទី ២៖ ការអប់រំរបស់កុមារី និងការប្រែប្រួលអាកាសធាតុ

- ពន្យល់ថាឥលូវនេះយើងនឹងពិនិត្យមើលការអប់រំរបស់កុមារី និងការប្រែប្រួលអាកាសធាតុ។ សួរសិស្សានុសិស្សថាតើពួកគេគិតថាបញ្ហាទាំងពីរអាចទាក់ទងនឹងគ្នាយ៉ាងដូចម្តេច។ ហេតុអ្វីបានជាការអប់រំរបស់កុមារីជាបញ្ហាយុត្តិធម៌អាកាសធាតុ?
- លោកគ្រូអ្នកគ្រូអាចផ្តល់ជាតម្រុយថាតើចំណុចទាំងពីរមានទំនាក់ទំនងបែបអវិជ្ជមាន និងវិជ្ជមានយ៉ាងដូចម្តេចខ្លះ។

  **ផលប៉ះពាល់អវិជ្ជមានរួមមាន៖**

  - កុមារីនៅក្នុងគ្រួសារដែលងាយរងគ្រោះទំនងជាចាកចេញពីសាលារៀន ដើម្បីរៀបការនៅពេលមានវិបត្តិពាក់ព័ន្ធនឹងអាកាសធាតុ ដើម្បីជួយសម្រាលបន្ទុកធនធានគ្រួសារដែលខ្វះខាត។
  - គ្រួសារតែងតែដកកុមារីចេញពីសាលារៀន ឬពុំបានបញ្ជូនកុមារីឲ្យទៅសាលារៀនបានញឹកញាប់ ក្នុងពេលមានគ្រោះរាំងស្ងួត ពីព្រោះបទដ្ឋានយេនឌ័រកំណត់ថាការងារដងទឹកគឺជាការងារកុមារី និងស្ត្រី។
  - គ្រោះរាំងស្ងួតអាចធ្វើឲ្យកុមារីខកខានការសិក្សានៅពេលមានរដូវ ដោយសារកង្វះទឹកដើម្បីរក្សាអនាម័យពេលមករដូវ។
  - ព្រឹត្តិការណ៍ដែលពាក់ព័ន្ធនឹងអាកាសធាតុអាចនាំទៅដល់ការបិទសាលារៀន ឬការកើនឡើងការធ្វើចំណាកស្រុក ដែលប៉ះពាល់ដល់កុមារីក្នុងទំហំខុសៗគ្នា។
  - នៅក្នុងព្រឹត្តិការណ៍នៃការបិទសាលារៀនដែលពាក់ព័ន្ធនឹងអាកាសធាតុ កុមារីទំនងជាបានវិលត្រលប់ចូលរៀនវិញតិចជាងកុមារានៅសាលារៀនបណ្តោះអាសន្ន ដោយសារការភ័យខ្លាចរបស់គ្រួសារថាកូនស្រីរបស់ខ្លួនអាចត្រូវបានគេយាយី ឬជួបប្រទះអំពើហិង្សានៅពេលពួកគេធ្វើដំណើរទៅ ឬមកពីកន្លែងបណ្តោះអាសន្ននោះ។
  - ការប្រែប្រួលអាកាសធាតុអាចធ្វើឲ្យកម្រិត និងទំហំនៃជំងឺដែលមនុស្សកំពុងប្រឈមខុសៗគ្នា (ឧទាហរណ៍ ជំងឺរាតត្បាតកូវីដ-១៩) ដែលបណ្តាលឲ្យវត្តមានកុមារីក្នុងសាលារៀនធ្លាក់ចុះ និងបង្កើនអត្រាបោះបង់ចោលការសិក្សាសម្រាប់កុមារី។

  **ផលប៉ះពាល់ជាវិជ្ជមានរួមមាន៖**

  - នៅពេលកុមារីទៅសាលារៀន ពួកគេរៀនជំនាញក្នុងការប្រមើមើល និងយកឈ្នះលើវិបត្តិដែលពាក់ព័ន្ធនឹងអាកាសធាតុ ដូចជាសមត្ថភាពនៃការគិតពិចារណាដែលចាំបាច់ដើម្បីដំណើរការ និងចាត់វិធានការក្រោយមានការរាយការណ៍អំពីអាកាសធាតុ។
  - ការអប់រំក៏បង្កើនភាពធន់នឹងអាកាសធាតុ និងសមត្ថភាពបន្សាំផងដែរ។
  - ស្ត្រីវ័យក្មេងដែលមានការអប់រំទំនងជាចូលរួមក្នុងសកម្មភាពសមូហភាព និងការផ្លាស់ប្តូរប្រព័ន្ធឆ្ពោះទៅរកនិរន្តរភាពច្រើនជាងមុន។
  - បណ្តាប្រទេសដែលបានវិនិយោគលើការអប់រំកុមារី បានទទួលរងការស្លាប់ដោយសារគ្រោះរាំងស្ងួត និងទឹកជំនន់តិចជាងប្រទេសដែលមានកម្រិតអប់រំកុមារីទាបជាង។
  - ការអប់រំរបស់កុមារី ជាពិសេសការអប់រំនៅកម្រិតមធ្យមសិក្សាត្រូវបានគេកំណត់ថាជាកត្តាកំណត់សេដ្ឋកិច្ចសង្គមដ៏សំខាន់បំផុត ដើម្បីកាត់បន្ថយភាពងាយរងគ្រោះទៅនឹងផលប៉ះពាល់នៃគ្រោះមហន្តរាយដែលពាក់ព័ន្ធនឹងអាកាសធាតុ និងព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ។ [10]

- ដើម្បីបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ សហគមន៍ត្រូវមានភាពធន់ជាងមុន។ អ្នកអាចប្រើសកម្មភាពនេះដើម្បីបង្ហាញពីភាពធន់។ យកម្ជុល ប៉េងប៉ោង និងបាល់អេប៉ុង។ សួរសិស្សានុសិស្សថាតើនឹងមានអ្វីកើតឡើងនៅពេលអ្នកចាក់ទាំងបាល់អេប៉ុង និងប៉េងប៉ោងដោយប្រើម្ជុល។ បាល់អេប៉ុងស្រូបយកការចាក់ចូលរបស់ម្ជុល តែប៉េងប៉ោងបែរជាផ្ទុះ។ ពន្យល់ថាប្រសិនបើការចាក់ម្ជុលត្រូវបានចាត់ទុកថាជា "គ្រោះមហន្តរាយ" នោះ "ភាពធន់" គឺជាសមត្ថភាពរបស់យើងក្នុងការទទួលយកវិបត្តិនោះ។ ដូច្នេះ ផ្ទុយពីប៉េងប៉ោងដែលមិនអាចទ្រាំទ្រនឹងគ្រោះមហន្តរាយនោះ បាល់អេប៉ុងនេះអាចស្រូបយកវិបត្តិ ដែលនេះហើយគឺជាភាពធន់ខ្លាំង។ នេះជាអ្វីដែលយើងមានគោលបំណងសម្រេចបានតាមរយៈការកសាងភាពធន់នឹងការបង្កើនសមត្ថភាពកសាងឡើងវិញ។ អ្នកក៏អាចប្រើប្រាស់របស់លេង "ស្លីងគី" (ជារបស់លេងរមូលដូចរឺស័រ) ដើម្បីពន្យល់ពីគោលគំនិតនៃការឡងត្រលប់មកវិញ ឬការវិលត្រលប់ទៅទីតាំងដើមវិញ។ [11]
- សូមមើលស្លាយទី ២១ អំពីការអប់រំរបស់កុមារី។ ពិភាក្សាអំពីរបៀបដែលជម្រើសទាំងនេះមិនស្ថិតក្រោមការគ្រប់គ្រងរបស់កុមារី ដូច្នេះការពិភាក្សាអំពីការដោះស្រាយវិសមភាពយេនឌ័រចាំបាច់ត្រូវមាននៅគ្រប់កម្រិតនៃសង្គមជាមួយគ្រួសារ, លោកគ្រូអ្នកគ្រូ, អ្នកដឹកនាំសហគមន៍, និងអ្នកនយោបាយ។
- សូមក្រឡេកមើលព័ត៌មានស្តីពីវិសមភាពយេនឌ័រ និងការប្រែប្រួលអាកាសធាតុនៅលើស្លាយទី ២២។ សម្រាប់សេចក្តីថ្លែងការណ៍នីមួយៗនេះ សូមឲ្យសិស្សានុសិស្សបង្ហាញអំពីហេតុផលដែលថាហេតុអ្វីបានជាករណីនេះកើតឡើង។ សិស្សានុសិស្សប្រហែលជាចង់យោងទៅស្លាយទី ១៧។ តើនេះសមភាព សមធម៌ និងយុត្តិធម៌ដែរឬទេ? តើយើងអាចធ្វើអ្វីបាន?

[10] អនាគតដ៏បៃតង និងយុត្តិធម៌ជាងមុន៖ ហេតុអ្វីបានជាអ្នកដឹកនាំត្រូវវិនិយោគលើអាកាសធាតុ និងការអប់រំកុមារី (មូលនិធិម៉ាឡាឡា ២០២១) https://malala.org/newsroom/archive/malala-fund-publishes-report-on-climate-change-and-girls-education

[11] កែសម្រួលពី សៀវភៅណែនាំបណ្តុះបណ្តាលស្តីពីយេនឌ័រ និងធន់នឹងអាកាសធាតុ ២០២១ មជ្ឈមណ្ឌលធនធានអាស៊ីប៉ាស៊ីហ្វិកសម្រាប់ស្ត្រី https://www.empowerforclimate.org/en/resources/t/r/a/training-manual-on-gender-and-climate-resilience

### ការណែនាំសម្រាប់ការពន្យល់សេចក្ដីថ្លែងការណ៍៖

ក. រដ្ឋាភិបាលភាគច្រើននៅជុំវិញពិភពលោកនៅតែគ្រប់គ្រងដោយបុរស។ អ្នករៀបចំព្រឹត្តិការណ៍បែបនេះត្រូវធានាឲ្យមានតំណាងស្មើៗគ្នា ហើយថាប្រតិភូទាំងអស់ទទួលបានពេលវេលាស្មើគ្នាក្នុងការនិយាយ។ សូមមើលយុទ្ធនាការ "នាងផ្លាស់ប្ដូរអាកាសធាតុ" សម្រាប់ ៥០ ភាគរយនៃភាពជាអ្នកដឹកនាំវិបត្តិអាកាសធាតុជាស្ត្រី។

ខ. ដោយសារភាពងាយរងគ្រោះរបស់មនុស្សចំពោះហានិភ័យភាគច្រើនអាស្រ័យលើទ្រព្យសម្បត្តិ និងធនធានដែលខ្លួនមានលទ្ធភាពមានទ្រព្យសម្បត្តិតិចតួចរបស់កុមារី និងស្ត្រី ធ្វើឲ្យខ្លួនកាន់តែងាយរងគ្រោះចំពោះគ្រោះធម្មជាតិ។ ការបង្កើនសមភាពយេនឌ័រ និងលទ្ធភាពទទួលបានឱកាសអប់រំ និងសេដ្ឋកិច្ច មានសារៈសំខាន់ណាស់ក្នុងការកសាងភាពធន់សហគមន៍ក្នុងពេលកំពុងប្រឈមនឹងការប្រែប្រួលអាកាសធាតុ។ [12]

គ. សង្គមជាច្រើននៅពុំទាន់ផ្ដល់តម្លៃដល់កុមារីឲ្យស្មើភាពគ្នានឹងកុមារាឡើយ។ សង្គមទាំងនោះចាំបាច់ទទួលស្គាល់អំពីអត្ថប្រយោជន៍ចំពោះសហគមន៍កុមារីទាំងអស់ដែលមានលទ្ធភាពបញ្ចប់ការអប់រំរបស់ខ្លួន និងធ្វើការសម្រេចចិត្តលើខ្សែជីវិតរបស់ខ្លួនផ្ទាល់។

ឃ. ការងារបច្ចេកទេស និងវិស្វកម្ម ដែលរំពឹងថានឹងមានកំណើនច្រើនជាងគេ នៅតែភាគច្រើនជាបុរស។ ស្ត្រីត្រូវមានការលើកទឹកចិត្តឲ្យចូលរួមជាមួយបច្ចេកវិទ្យាបៃតង និងដើម្បីក្លាយជាសហគ្រិន។

- សូមមើលស្លាយទី ២៣ ភាពជាអ្នកដឹកនាំរបស់ស្ត្រី និងការប្រែប្រួលអាកាសធាតុ, ស្លាយទី ២៤ ការកេងប្រវ័ញ្ចមនុស្ស និងភពផែនដី និងស្លាយទី ២៥ ផ្នែកសំខាន់ៗសម្រាប់ការអប់រំរបស់កុមារី។ [13]

អ្នកក៏អាចសុំឲ្យពួកគេមើលស្លាយទី ២១ និង ២២ វិញផងដែរ។ ឲ្យសិស្សានុសិស្សស្វែងរកមូលហេតុចំនួនប្រាំហេតុអ្វីបានជាការអប់រំរបស់កុមារីមានសារៈសំខាន់ក្នុងការប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ។ សុំឲ្យពួកគេត្រៀមខ្លួនដើម្បីផ្ដល់ហេតុផល។

### ការសង្ខេបរបស់គ្រូ៖ គំនិតដែលបានមកពីការស្រាវជ្រាវ

- គុណតម្លៃ និងជំនឿដែលបញ្ជាក់អំពីការកេងប្រវ័ញ្ច និងការរំលោភបំពានលើកុមារី និងស្ត្រី គឺចាក់ឫសគល់ទៅក្នុងគុណតម្លៃ និងជំនឿដូចគ្នា ដែលបង្ហាញអំពីការកេងប្រវ័ញ្ច និងការរំលោភបំពានលើបរិស្ថាន និងពិភពដែលមិនមែនជាមនុស្ស៖ ភាគច្រើន ការផាត់ចេញ និងការជះឥទ្ធិពលគ្រប់គ្រង។

- តាមរយៈការធ្វើបរិវត្តកម្មគោលបំណងនៃការអប់រំដើម្បីបង្កើតសង្គមសមធម៌យេនឌ័រឲ្យកាន់តែច្រើន និងតាមរយៈការបង្រៀនសមភាពយេនឌ័រយ៉ាងសកម្ម និងគោលការណ៍សមធម៌, យុត្តិធម៌, និងសមភាព យើងអាចដោះស្រាយគុណតម្លៃ ក្រមសីលធម៌ រចនាសម្ព័ន្ធ និងទំនាក់ទំនងនៃអំណាចក្នុងពេលតំណាលគ្នា ដើម្បីបង្កើតសង្គមដែលមាននិរន្តរភាពផ្នែកសេដ្ឋកិច្ច សង្គម និងបរិស្ថាន។ [14]

### កិច្ចសហការដែលអាចមានជាមួយអ្នកដទៃ

គេអាចចែករំលែក និងពិភាក្សាចម្លើយរបស់សិស្សានុសិស្សនៅក្នុងសកម្មភាពសិក្សាជំហានទី ៣ ផ្នែកទី ២ ជាមួយថ្នាក់រៀនមកពីសាលារៀនផ្សេងទៀតនៅក្នុងតំបន់ ឬប្រទេសផ្សេងបាន។



[12] គរុកោសល្យដែលឆ្លើយតបនឹងយេនឌ័រ៖ កញ្ចប់ឧបករណ៍សម្រាប់គ្រូបង្រៀន និងសាលារៀន បោះពុម្ពលើកទី ២ (២០១៨) ។ វេទិកាសម្រាប់អ្នកអប់រំស្ត្រីអាហ្វ្រិក (FAWE) https://www.unicef.org/esa/media/6726/file/GRP-A-Toolkit-for-Teachers-and-Schools-2020.pdf (ទំព័រ ១០៤)

[13] សម្របចេញពី 'វេទិកាបីសម្រាប់ការអប់រំរបស់កុមារីក្នុងយុទ្ធសាស្ត្រអាកាសធាតុ' Christina Kwauk និង Amanda Braga វិទ្យាស្ថាន Brookings ២០១៧ វេទិកា 3 សម្រាប់ការអប់រំរបស់កុមារីក្នុងយុទ្ធសាស្ត្រអាកាសធាតុ (brookings.edu)

